# កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
# គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

~~~~~~~~~~~~~

# របាយការណ៍វឌ្ឍនភាព ឆ្នាំ២០០៩

### លេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាកម្មវិធីកំណែទម្រង់ជាអាទិភាពនៃយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល ដែលបានចាប់ផ្តើមនៅក្នុងខែធ្នូ ឆ្នាំ២០០៤ក្នុងគោលដៅប្រែក្លាយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជាឱ្យទៅជាប្រព័ន្ធមួយដែលមានលក្ខណៈស្របទៅតាមនិយាមអន្តរជាតិ ដែលមានការទទួលស្គាល់ជាទូទៅនៅត្រឹមឆ្នាំ ២០១៥។

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំជាបួនជំហានដែលត្រូវដាក់អនុវត្តជាដំណាក់កាល។ ដើម្បីសម្រេចនូវគោលដៅចំបងនៃជំហាននីមួយៗ (១)ការបង្កើនភាពជឿទុកចិត្តបាននៃថវិកា (២) ករបង្កើនគណនេយ្យភាពហិរញ្ញវត្ថុដើម្បីធ្វើឱ្យប្រសើរឡើងការត្រួតពិនិត្យផ្ទៃក្នុង និងគណនេយ្យភាពរបស់អ្នកគ្រប់គ្រងថវិកា (៣)ការផ្សារភ្ជាប់គ្នារវាងថវិកា និងគោលនយោបាយ និង(៤)បង្កើនគណនេយ្យភាពសមិទ្ធកម្មរបស់អ្នកគ្រប់គ្រង។

នៅក្នុងដំណាក់កាលនីមួយៗ ផែនការសកម្មភាពច្បាស់លាស់ត្រូវបានរៀបចំ និងកំណត់ដើម្បីសម្រេចគោលដៅជាយុទ្ធសាស្រ្តតាមជំហាននីមួយៗ ព្រមទាំងការដាក់ចេញសកម្មភាពគាំទ្រដទៃទៀតដោយផ្សារភ្ជាប់ជាមួយយន្តការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ផ្អែកលើកន្សោមសូចនាករណ៍សមិទ្ធកម្មដែលបានដកស្រង់ចេញពីក្របខ័ណ្ឌការងារគណនេយ្យភាពហិរញ្ញវត្ថុ និងចំណាយសាធារណៈ។

របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ២០០៩ នៃការអនុវត្តកម្មវិធីកែទម្រង់ដំណាក់កាលទី ២ នេះនឹងធ្វើការបង្ហាញអំពីសកម្មភាពការងារកំណែទម្រង់ដែលបានអនុវត្តដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ នៅឆ្នាំ ២០០៩ ដោយធ្វើការបង្ហាញឱ្យឃើញអំពីស្ថានភាពនៃការអនុវត្តសកម្មភាពកំណែទម្រង់ដំណាក់កាលទី ២ ដែលមានកំណត់នៅក្នុងផែនការសកម្មភាពរួម ព្រមទាំងបញ្ហាប្រឈមមួយចំនួនដែលបានជួបប្រទះដើម្បីស្វែងរកដំណោះស្រាយ។ របាយការណ៍នេះក៏នឹងបង្ហាញឱ្យឃើញនូវវឌ្ឍនភាពក្នុងវិស័យគោលគន្លឹះនៃការបន្តរក្សាភាពជឿទុកបាននៃថវិកាដែលជាសមិទ្ធផលដំណាក់កាលទី១/ជំហានទី១។
~~~~~~~~~~~~~

## ១. វឌ្ឍនភាពផ្នែកតាមសូចនាករក្នុងវិស័យគោលគន្លឹះនៃដំណាក់កាលទី ១/ជំហានទី ១

ភាពជឿទុកបាននៃថវិកាត្រូវបានបន្តពិនិត្យតាមដាននៅក្នុងដំណាក់កាលទី២តាមរយៈការពិនិត្យបណ្តាសូចនាករដែលអាចវាស់វែងជាបរិមាណបាននៃជំហានទី១ ដែលមានបង្ហាញជូននៅក្នុងតារាងខាងក្រោមៈ

| សូចនាករ | គោលដៅ | វឌ្ឍនភាពឆ្នាំ ២០០៩ | វឌ្ឍនភាពឆ្នាំ ២០០៨ |
|---|---|---|---|
| ១.លទ្ធផលចំណូលក្នុងស្រុកសរុបជាបណ្តើៗកាន់តែខិតទៅរកគោលដៅដែលបានអនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុ | ចំណូលក្នុងស្រុកសរុបសំរេចបាន + ឬ - 5% ធៀបនឹងគោលដៅដែលបានអនុម័តនៅក្នុងច្បាប់ | ចំណូលក្នុងស្រុកៈ ៩៥.១% (តួលេខបណ្តោះអាសន្ន) | ចំណូលក្នុងស្រុកៈ១៣២.៧% |
| ២.គ្មានការបង្កើតឡើងនូវបំណុលកកស្ទះថ្មី | បំណុលកកស្ទះត្រូវកម្រិតមិនឱ្យលើសពី ២% នៃចំណាយសរុប | មិនមានបំណុលកកស្ទះ | មិនមានបំណុលកកស្ទះ |
| ៣.អាណាប័កជាបណ្តើៗអាចបញ្ជាចំណាយទៅតាមកម្មវិធីចំណាយ និងផែនការសាច់ប្រាក់ | ស្ថានភាពចំណាយមិនត្រូវតិចជាងៈ<br>- ត្រីមាសទី១ៈ ១៥%<br>- ត្រីមាសទី២ៈ ៤៥%<br>- ត្រីមាសទី៣ៈ ៦៧%<br>- ត្រីមាសទី៤ៈ ៩៦%<br>ភាគរយនៃការទូទាត់ជូនអ្នកផ្គត់ផ្គង់និងបុគ្គលិកតាមប្រព័ន្ធធនាគារមិនត្រូវតិចជាង ៨០%នៃចំណាយសរុប<br><br>ភាគរយនៃការបង់ចំណូលតាមរយៈប្រព័ន្ធធនាគារមិនត្រូវតិចជាង៦០%នៃចំណូលសរុប | សម្រេចបានក្នុងៈ<br><br>- ត្រីមាសទី១ៈ ១៧.៩%<br>- ត្រីមាសទី២ៈ ៤១.៨%<br>- ត្រីមាសទី៣ៈ ៧១.៣%<br>-ត្រីមាសទី៤ៈ ៩៥.៩%<br><br>-ការទូទាត់តាមប្រព័ន្ធធនាគារសម្រេចបាន៨២.១៤%<br><br>-ក្រសួងចំនួន ២៦ បានបើកបៀវត្សតាមប្រព័ន្ធធនាគារ<br>-ចំណូលពន្ធគយៈ ៩៨.៦%<br>-ចំណូលពន្ធដារៈ ៩០.៧% | សម្រេចបានក្នុងៈ<br><br>-ត្រីមាសទី១ៈ ១៤.៧%<br>-ត្រីមាសទី២ៈ ៤៣.៨%<br>-ត្រីមាសទី៣ៈ ៧១.៧%<br>-ត្រីមាសទី៤ៈ ១០៧.៤% |
| ៤.ចំណាយតាមប្រភេទ (សម្រាប់បុគ្គលិក និង មិនមែនបុគ្គលិក)កាន់តែខិតទៅរកថវិកាដែលបានអនុម័ត | លទ្ធផលចំណាយធៀបនឹងថវិកាអនុម័តមិនត្រូវតិចជាងៈ<br>-បៀវត្សៈ ៩៨%<br>-ទំនិញ/សេវាកម្មៈ ៩៥%<br>-មូលធនៈ ៨៥% | សម្រេចបានៈ<br><br><br>-បៀវត្សៈ ១០៧.៨%<br>-ទំនិញ/សេវាៈ ១០៦.៧%<br>-មូលធនៈ ៩៣.៥% | សម្រេចបានៈ<br><br><br>-បៀវត្សៈ ១១៥.៨%<br>-ទំនិញ/សេវាៈ១២៤.១%<br>-មូលធនៈ ៩៧.៩% |
| ៥.ទិន្នផលចំណូលលើមូលដ្ឋានពន្ធកាន់តែប្រសើរជាងមុនតាមរយៈការកែលម្អប្រសិទ្ធភាពនៃការប្រមូល និងផែនការប្រើប្រាស់ប្រភពចំណូលមិនមែនសារពើពន្ធ | ការរួមចំណែកទៅក្នុង ផសសនៃចំណូលសរុបមានការកែលម្អដោយបង្កើនប្រមាណ ០.៥%ក្នុងមួយឆ្នាំ | -ចំណូលពន្ធៈ ៩៧.២%<br>.ពន្ធផ្ទាល់ៈ ៩៩.៥.%<br>.ពន្ធប្រយោលៈ ៩៦.៧%<br>-ចំណូលមិនមែនសារពើពន្ធៈ ៨៦.៦% | -ចំណូលពន្ធៈ ១៣៤%<br>.ពន្ធផ្ទាល់ៈ ១៣៤.៥%<br>.ពន្ធប្រយោលៈ ១៣៣.៩%<br>-ចំណូលមិនមែនសារពើពន្ធ ៈ ១៣៥% |
| ៦.រាល់ផ្នែកសំខាន់ៗនៃចំណូល និងចំណាយសាធារណៈត្រូវបានដាក់បញ្ចូលក្នុងថវិកា | មិនមានផ្នែកសំខាន់ៗដែលត្រូវបានដកចេញ | -បានបន្តពង្រឹងគណនីទោលរតនាគារ និងការប្រមូលផ្តុំគណនីរដ្ឋាភិបាល, | -គណនីទោលរតនាគារនិងការប្រមូលផ្តុំគណនីរដ្ឋាភិបាលត្រូវបានពង្រឹង |

| | | | |
|---|---|---|---|
| និងគណនីរបស់រដ្ឋាភិបាល | | ដាក់ឱ្យអនុវត្តប្លង់ គណនេយ្យថ្មី, ចំណាត់ថ្នាក់ថវិកាថ្មីនិងផែនការយុទ្ធសាស្ត្រថវិកាបានរួមចំណែកដល់ការកែលម្អការដាក់បញ្ចូលចំណូលនិងចំណាយក្នុងគណនីរដ្ឋាភិបាល។ ណែនាំឱ្យមានការបញ្ចូលក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១០-២០១២ នូវចំណូល-ចំណាយរបស់សហគ្រាសពាណិជ្ជ និង ឧស្សាហកម្ម ថវិការបស់គ្រឹះ ស្ថានសាធារណៈរដ្ឋបាលនិងថវិកាក្រៅបរិបថរបស់ដៃគូអភិវឌ្ឍន៍<br>- គណនីចរន្តទូទាំងប្រទេសបានថយចុះមកត្រឹមចំនួន ៩០ គណនី<br>-ប្រព័ន្ធទិន្នន័យ(DMFAS) បានដំណើរការដើម្បីកែលម្អការគ្រប់គ្រង និងត្រួតពិនិត្យហិរញ្ញប្បទានពីខាងក្រៅ | ប្លង់គណនេយ្យថ្មី, ចំណាត់ថ្នាក់ថវិកាថ្មីនិងផែនការយុទ្ធសាស្ត្រថវិកាត្រូវបានដាក់ឱ្យអនុវត្ត។<br>- នៅដើមឆ្នាំ២០០៩ គណនីចរន្តរបស់ក្រសួងស្ថាប័ន នៅធនាគារពា-ណិជ្ជ និង ធនាគារជាតិមានចំនួន១៨៧ គណនីចរន្តចំនួន ១៣ ត្រូវបានបិទនិងបានបង្អក គណនីចរន្តចំនួន ៤២<br>-ប្រព័ន្ធទិន្នន័យ (DMFAS) ត្រូវបានដាក់ឱ្យដំណើរការ |

## ២. ការវាស់វែងសមិទ្ធកម្មសម្រាប់ការអនុវត្តសកម្មភាពកំណែទម្រង់ដំណាក់កាលទី២

ការត្រួតពិនិត្យមើលការអនុវត្តសកម្មភាពកំណែទម្រង់ដំណាក់កាលទី២ បានផ្តោតលើវឌ្ឍនភាពនៃផែនការសកម្មភាពទាំងបីប្រភេទដែលបានកំណត់នៅក្នុងផែនការសកម្មភាពរួមនោះគឺ ការពិនិត្យមើលវឌ្ឍនភាពសកម្មភាពជំហានទី១ដែលត្រូវបន្តពង្រឹងក្នុងដំណាក់កាលទី២, វឌ្ឍនភាពសកម្មភាពដើម្បីសម្រេចគោលបំណងផ្ទាល់នៃជំហានទី ២ និងវឌ្ឍនភាពសកម្មភាពសម្រាប់ជំហានបន្ទាប់។

### ២.១ សកម្មភាពជំហានទី១ ដែលត្រូវបន្តពង្រឹងនៅក្នុងដំណាក់កាលទី២

ការពិនិត្យមើលវឌ្ឍនភាពនៃសកម្មភាពទាំងនេះ ដែលរៀបចំក្រោមគោលបំណងចំនួនបួន គឺដើម្បីធានាថាភាពជឿទុកចិត្តបាននៃថវិកាដែលជាសមិទ្ធផលនៃការអនុវត្តកម្មវិធីកំណែទម្រង់ដំណាក់កាលទី១នៅតែរក្សាបាន ដើម្បីគាំទ្រដល់ការសម្រេចគោលបំណងនៃកំណែទម្រង់ជំហាន ទី២ "**ការធ្វើឱ្យប្រសើរឡើងគណនេយ្យភាពហិរញ្ញវត្ថុ**" ។

### . បន្តកែលម្អរដ្ឋបាល និង គោលនយោបាយចំណូល

#### *ផ្នែកចំណូលមិនមែនសារពើពន្ធ*

នៅក្នុងក្របខ័ណ្ឌនៃការរៀបចំផ្នែកស្ថាប័ន សម្រេចបានការបង្កើតអនុក្រុមការងារគ្រប់គ្រងចំណូលពីប្រតិបត្តិការអាជីវកម្មធនធានរ៉ែធម្មជាតិ គណៈកម្មាធិការអន្តរក្រសួងដើម្បីស្រាវជ្រាវតាក់តែងសេចក្តីព្រាងច្បាប់ស្តីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ កែសម្រួលសមាសភាពគណៈកម្មាធិកាឯកជនភាវូបនីយកម្ម ក្រុមការងារតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ គណៈកម្មាធិការអន្តរក្រសួងដើម្បីរៀបចំយន្តការគ្រប់គ្រងចំណូលសេវាចុះបញ្ជីយានយន្ត និងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ ក្រុមការងារអន្តរក្រសួងក្នុងការត្រួតពិនិត្យការគ្រប់គ្រងចំណូល និងបំណុលសេវាទូរគមនាគមន៍ ក្រុមការងារអន្តរក្រសួងដើម្បីចុះពិនិត្យការគ្រប់គ្រង និងការអនុវត្តចំណូលរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រុមការងារអន្តរក្រសួងដើម្បីគ្រប់គ្រងអាជីវកម្មអភិវឌ្ឍន៍អចលនវត្ថុ គណៈកម្មាធិការអន្តរក្រសួងដើម្បីរៀបចំយន្តការគ្រប់គ្រង និងជំរុញឱ្យមានការទិញធានារ៉ាប់រងចំពោះយានយន្តតតិយជន ការដ្ឋាននិងការដឹកជញ្ជូនអ្នកដំណើរ សមាគមវាយតម្លៃអចលនវត្ថុ និងចូលជាសមាជិកសមាគមវាយតម្លៃអចលនវត្ថុអាស៊ាន។

ព្រមជាមួយនេះ លិខិតបទដ្ឋានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធជាច្រើនក៏ត្រូវរៀបចំរួចរាល់ដែលក្នុងនោះរួមមានៈ ប្រកាសធានារ៉ាប់រងជីវិត, ប្រកាសស្តីពីគោលការណ៍ណែនាំផ្នែកគណនេយ្យ, ក្របខ័ណ្ឌគោលនយោបាយ និងយុទ្ធសាស្រ្តមីក្រូហិរញ្ញវត្ថុ លិខិតបទដ្ឋានពាក់ព័ន្ធនឹងការប្រមូលចំណូលពីឆ្នោតឡូតូ ប្រកាសស្តីពីការគ្រប់គ្រងការត្រួតពិនិត្យ និងការផ្តល់អាជ្ញាប័ណ្ណដល់បុគ្គលអភិវឌ្ឍន៍អចលន

ទ្រព្យ ហើយក៏បានកំពុងរៀបចំឯកសារមួយចំនួនទៀតដូចជា៖ សេចក្តីព្រាងនីតិវិធីដើម្បីត្រួតពិនិត្យអនុបំណុលរបស់រដ្ឋាភិបាលនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និង ការសិក្សាស្រាវជ្រាវរៀបចំគោលការណ៍ណែនាំស្តីពីការត្រួតពិនិត្យទុនអនុបំណុល, សេចក្តីព្រាងតារាងកម្រៃជើងសារសម្រាប់ក្រុមហ៊ុនប្រកបសេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ សេចក្តីព្រាងស្តង់ដាគ្រប់គ្រងសេវាកម្មអចលនវត្ថុ សេចក្តីព្រាងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់ក្រុមហ៊ុនប្រកបសេវាកម្មវាយតម្លៃនិងសេវាកម្មអចលនវត្ថុ សេចក្តីព្រាងអនុក្រឹត្យស្តីពីការបោះផ្សាយ និងជួញដូរមូលប័ត្រមហាជន សេចក្តីព្រាងប្រកាសថ្មីដើម្បីគ្រប់គ្រងអាជីវកម្មកាស៊ីណូ សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងឆ្នោត-ឡូតូ សេចក្តីព្រាងច្បាប់កាស៊ីណូ សេចក្តីព្រាងច្បាប់ Financial Trust Law ពិនិត្យកែលម្អសារាចរណែនាំស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃជាតិ សៀវភៅណែនាំស្តីពីការរៀបចំបញ្ជីសារពើភ័ណ្ឌ និងរៀបចំលក្ខខណ្ឌការងារសម្រាប់ក្រុមហ៊ុនសិក្សាការចុះបញ្ជីសារពើភ័ណ្ឌ ច្បាប់ស្តីពីការធានារ៉ាប់រង អនុក្រឹត្យ និងប្រកាសពាក់ព័ន្ធនឹងផ្នែកធានារ៉ាប់រង។

បន្ថែមលើនេះ សកម្មភាពការងារជាក់ស្តែងជាច្រើនត្រូវបានអនុវត្តនៅក្នុងឆ្នាំ ២០០៩ ដែលរួមមានការពង្រឹងការប្រមូលចំណូលមិនមែនសារពើពន្ធ (កម្រៃសេវា ភាគលាភនៃប្រាក់ចំណេញ ឯកជនភាវូបនីយកម្ម ការជួលអចលនទ្រព្យ ចំណូលរ៉ែ ឈ្នួលដីសម្បទាន ចំណូលសត្តឃាត ភាស៊ីផ្សារ និងចំណូលផ្សេងទៀត) ពង្រឹងការគ្រប់គ្រង និងប្រមូលចំណូលកាស៊ីណូ បង្កើតយន្តការត្រួតពិនិត្យសម្ភារៈល្បែងស៊ីសង, បានធ្វើការពិនិត្យស្រាវជ្រាវចំណូល-ចំណាយរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនិងសាកលវិទ្យាល័យរដ្ឋ ត្រួតពិនិត្យការបង់ចំណូលនៅរាជធានី-ខេត្តនិងស្រាវជ្រាវប្រភពចំណូលថ្មី, រៀបចំរបាយការណ៍ចំណូលពីថ្លៃឈ្នួលផ្ទៃក្រឡាដីសម្បទានរ៉ែ និងតារាងកិច្ចព្រមព្រៀងសម្បទានរ៉ែប្រចាំឆ្នាំ២០០៨ របាយការណ៍ចំណូលថ្លៃសួយសារវត្ថុធាតុដើមថ្មនិង សម្ភារៈសំណង់ឆ្នាំ២០០៨, ការកំណត់តម្លៃអាករអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ តម្លៃព្រឹត្តិបត្រថ្កោលទោស តម្លៃលេខចុះបញ្ជីរថយន្តធុនទេសចរណ៍ តម្លៃសេវាកម្មសាធារណៈសម្រាប់ការចុះបញ្ជីគំនូរឧស្សាហកម្ម កម្រៃសេវាប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានប្រយោជន៍, ការត្រៀមរៀបចំប្រកាសអន្តរក្រសួងគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ. ក្រុមបេសកកម្មរបស់នាយកដ្ឋានចំណូលមិនមែនសារពើពន្ធបានចុះទៅខេត្ត ចំនួន ០៦ដើម្បីពិនិត្យការប្រមូលចំណូលមិនមែនសារពើពន្ធ ផ្ទៀងផ្ទាត់ស្ថានភាពបំណុលនៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល, កំណត់លក្ខណៈវិនិច្ឆ័យក្នុងការផ្តល់ការលើកទឹកចិត្តចំពោះមន្ត្រីបំពេញការងារផ្នែកប្រមូលចំណូល ជំរុញការរៀបចំបញ្ជីសារពើភ័ណ្ឌគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ការវាយតម្លៃដី និងអគារក្រសួង-ស្ថាប័ន រាជធានី-ខេត្ត ការស្រង់ព័ត៌មានពីផ្នែកឯកជន ទាក់ទងនឹងវិស័យសហគ្រាសធុនតូច និងមធ្យម។

នៅក្នុងក្របខ័ណ្ឌការងារគ្រប់គ្រង និងប្រមូលចំណូលមិនមែនសារពើពន្ធ ក្រសួង-ស្ថាប័ន ក៏បាន និងកំពុងសហការក្នុងកិច្ចការទារបំណុល ប្រមូលចំណូល ថ្លៃឈ្នួលរោងចក្រ និង សម្បទានរ៉ែ ការរៀបចំរបាយការណ៍ស្តីពីស្ថានភាពចំណូលមិនមែនសារពើពន្ធប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ការប្រមូលព័ត៌មានស្តីពីប្រភពចំណូលមិនមែនសារពើពន្ធនៅក្នុងក្រសួង-ស្ថាប័ន និង ផ្តល់ធាតុចូលរៀបចំគោលនយោបាយចំណូលរយៈពេលមធ្យម និងការបង្កើតក្រុមការងារចំណូល។

## ***ផ្នែកចំណូលសារពើពន្ធ***

ការរៀបចំ និងពង្រឹងសមត្ថភាពផ្នែកស្ថាប័ន សម្រេចបានការបង្កើតក្រុមការងារណែនាំការប្រើប្រាស់បញ្ជីគណនេយ្យសម្រាប់អ្នកជាប់ពន្ធតូច និងមធ្យម កែលម្អរចនាសម្ព័ន្ធ និងរដ្ឋបាលសាខាពន្ធខណ្ឌ ក្រុមការងារកែសម្រួលសារាចរសវនកម្មផ្នែកពន្ធ ពង្រីកគម្រោងអាស៊ីគូដារើលជំហានទី ៣នៅទីតាំងបីបន្ថែមទៀត អនុម័តផែនការគោលសម្រាប់ក្រុមការងារតាមដាន ការអនុវត្តការងារកៀរគរនិងគ្រប់គ្រងចំណូលពីប្រេង ឧស្ម័ន និងធនធានរ៉ែ បង្កើតគណៈកម្មការអន្តរក្រសួងដើម្បីពិនិត្យគោលការណ៍ EITI រៀបចំផែនការសកម្មភាពដើម្បីកសាងសមត្ថភាពគ្រប់គ្រងឧស្សាហកម្មរុករកធនធានធម្មជាតិប្រកបដោយគណនេយ្យភាព និងតម្លាភាព និងដាក់ឱ្យអង្គការក្រៅរដ្ឋាភិបាលធ្វើការពិភាក្សា ផ្តល់ព័ត៌មានតាមគេហទំព័រក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអំពីចំណូលពីឧស្សាហកម្មរុករកធនធានធម្មជាតិ។

ទន្ទឹមនេះ សកម្មភាពពាក់ព័ន្ធដែលបានដាក់អនុវត្តរួចហើយរួមមាន ការរៀបចំគំរូសេដ្ឋកិច្ចវិភាគព្យាករណ៍ចំណូលក្រុមហ៊ុន និងរដ្ឋត្រូវទទួល ការរៀបចំសារាចរណែនាំស្តីពីការអនុវត្តខ្លឹមសារនៃមាត្រា ១៧នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ សៀវភៅផែនការយុទ្ធសាស្ត្រ និងកម្មវិធីការងារកំណែទម្រង់ និងទំនើបកម្មអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ការចងក្រង និងផ្សព្វផ្សាយសៀវភៅច្បាប់ និងបទបញ្ញត្តិគយ ក្រមសីលធម៌វិជ្ជាជីវៈគយ ប្រកាសស្តីពីវិធាន និងនីតិវិធីចាត់ទុកបំណុលពន្ធជាប្រាក់ពន្ធមិនអាចប្រមូលបាន សារាចរសវនកម្មសារពើពន្ធថ្មីទាំង០៥ (ការរៀបចំធ្វើសវនកម្ម ដំណើរការសវនកម្ម ផែនការ សវនកម្ម ឯកសារការងារ និងរបាយការណ៍សវនកម្ម) ប្រព័ន្ធរបបស្វ័យប្រកាស និងប្រព័ន្ធម៉ៅការតាមសាខាពន្ធដារខណ្ឌទាំង០៧ក្នុងរាជធានីភ្នំពេញ ប្រព័ន្ធកម្មវិធីគ្រប់គ្រងចំណូលពន្ធនៅតាមសាខាពន្ធដារខេត្ត-ខណ្ឌ កម្មវិធីគណនេយ្យ និងស្ថិតិពន្ធ កែសម្រួលសេចក្តីណែនាំអំពីសិទ្ធ និងកាតព្វកិច្ចអ្នកជាប់ពន្ធ រៀបចំសហគ្រាសទៅតាមប្រភេទធុរកិច្ច និងផែនការជ្រើសរើសអ្នកជាប់បំណុលពន្ធនៅនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងសាខាពន្ធដារខណ្ឌទាំង០៧ អនុវត្តវិធានការតឹងទារចំពោះសហគ្រាសចំនួន ២១៥ដែលជំពាក់បំណុលពន្ធ កែលម្អនិងដាក់អនុវត្តសេចក្តីជូនដំណឹងស្តីពីការកំណត់ពន្ធថ្មី ការដាក់ដំណើរការគេហទំព័រអគ្គនាយកដ្ឋានពន្ធដារ ។ ដោយឡែក សកម្មភាពការងារមួយចំនួនទៀតដែលកំពុង

អនុវត្តជាបណ្តើរៗមានដូចជា ការធ្វើបច្ចុប្បន្នភាពគោលនយោបាយចំណូល ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ពិនិត្យបញ្ចប់សេចក្តីព្រាងលើកទី៣នៃច្បាប់ស្តីពីពន្ធលើប្រេង និងកំពុងបញ្ចូលមតិយោបល់ផ្តល់ដោយ Chevron, CNPA និង IMF បន្តពិនិត្យច្បាប់ស្តីពីពន្ធលើដីធ្លីមិនប្រើប្រាស់ និងអាករស្នាក់នៅ ប្រកាសស្តីពីនីតិវិធីបណ្តឹងតវ៉ា សេចក្តីព្រាងប្រកាសស្តីពីការកំណត់និយមន័យឆ្នាំជាប់ពន្ធនៃពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំសម្រាប់ក្រុមហ៊ុនបរទេស សេចក្តីព្រាងអនុក្រឹត្យស្តីពីការកាត់បន្ថយកម្រិតផលរបរអាករលើតម្លៃបន្ថែមសម្រាប់បញ្ចូលក្នុងរបបស្វ័យប្រកាស សេចក្តីព្រាងប្រកាសស្តីពីពន្ធលើប្រាក់ចំណេញមូលធនពីអចលនទ្រព្យ(រូបវន្តបុគ្គល) សិក្សាការយកពន្ធលើវិស័យហិរញ្ញវត្ថុ សេចក្តីព្រាងច្បាប់ស្តីពីពន្ធលើអចលនទ្រព្យ រៀបចំបញ្ជីសហគ្រាសសម្រាប់កម្មវិធីសវនកម្មសារពើពន្ធ សេចក្តីព្រាងគោលនយោបាយស្តីពីព័ត៌មានវិទ្យានៅអគ្គនាយកដ្ឋានពន្ធដារ កំពុងរៀបចំប្រព័ន្ធទិន្នន័យពន្ធថ្នាក់កណ្តាល និងប្រព័ន្ធគ្រប់គ្រងទិន្នន័យពាក់ព័ន្ធ និងបង្កើត Intranet សម្រាប់អគ្គនាយកដ្ឋានពន្ធដារ និងសាងសង់អគារសាខាពន្ធដារនៅតាមខេត្ត ការបកប្រែគ្រឹសន្និសញ្ញាអំពីពន្ធ ការរៀបចំសារាចរស្តីពីវិធាន និងនីតិវិធីនៃការអង្កេតនិងប្រមូលផ្តុំព័ត៌មានផ្នែកពន្ធ ការរៀបចំផែនការធ្វើជំរឿនសហគ្រាសនៅរាជធានីភ្នំពេញ ការត្រៀមបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលផ្នែកពន្ធ ។

## - បន្តកែលម្អការគ្រប់គ្រងបំណុល

ការប្រើប្រាស់ប្រព័ន្ធ **DMFAS** ត្រូវបានបង្កើនប្រសិទ្ធភាពជាលំដាប់តាមរយៈការបង្កើនចំនួនស្ថានីយការងារ និងមន្ត្រីទទួលបន្ទុក ការពង្រឹងសមត្ថភាពមន្ត្រី ។ **DMFAS** ត្រូវបានប្រើប្រាស់សម្រាប់ការគ្រប់គ្រងព័ត៌មានស្តីពីហិរញ្ញប្បទានសម្បទានកម្ចីបន្ត និងហិរញ្ញប្បទានឥតសំណង។ មន្ត្រីពាក់ព័ន្ធទទួលបានការបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស និងចូលរួមវគ្គសិក្ខាសាលា (ហ្វីលីពីន ម៉ាឡេស៊ី ស្វីស) អំពីនៃការគ្រប់គ្រងបំណុល និងប្រើប្រាស់ប្រព័ន្ធ **DMFAS** និងការបង្កើនសមត្ថភាពផ្នែកមុខងារវិភាគលើការគ្រប់គ្រងហានិភ័យដើម្បីកែលម្អមុខងារគ្រប់គ្រងបំណុល ។ ទន្ទឹមនេះសិក្ខាសាលាផ្សព្វផ្សាយអំពីយុទ្ធសាស្ត្រគ្រប់គ្រងបំណុល និងមុខងារដទៃទៀតរបស់ **DMFAS** ក៏ត្រូវបានរៀបចំសម្រាប់មន្ត្រីនៃនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ និងនាយកដ្ឋានពាក់ព័ន្ធដទៃទៀត។ ទន្ទឹមនេះ សេចក្តីព្រាងគោលការណ៍ណែនាំក្នុងការគ្រប់គ្រងបំណុលត្រូវបានរៀបចំឡើង ហើយដំណើរការរៀបចំសេចក្តីព្រាងអនុក្រឹត្យលើការគ្រប់បំណុលសាធារណៈឱ្យស្របតាមការអនុវត្តជាអន្តរជាតិ និងស្របតាមស្ថានភាពប្រទេសកម្ពុជា នៅរង់ចាំជំនួយបច្ចេកទេសដែលគ្រោងនឹងមកដល់នៅខែមីនា ឆ្នាំ២០១០។

- **បន្តកែលម្អការគ្រប់គ្រងសាច់ប្រាក់ និង ការគ្រប់គ្រងគណនីធនាគារ**

នៅដើមឆ្នាំ២០០៩ គណនីចរន្តសរុបមានចំនួន១៧៤ ក្នុងស្មារតីនៃការពង្រឹងប្រសិទ្ធភាពគ្រប់គ្រងគណនីរដ្ឋនៅតាមបណ្តាធនាគារ វិធានការបង្អក និងបិទគណនីត្រូវបានអនុវត្តជាហូរហែ ដែលជាលទ្ធផលគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ គណនីចរន្តទូទាំងប្រទេសបានថយចុះមកត្រឹមចំនួន ៩០គណនី (ដែលសុទ្ធជាគណនីនៅថ្នាក់មូលដ្ឋាន)។ គណនីរបស់អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករ មានសមតុល្យសូន្យនៅរៀងរាល់ចុងថ្ងៃ។ វិធានការណ៍ដើម្បីបិទគណនីគម្រោងដែលបានបញ្ចប់រួចហើយ កំពុងដំណើរការជាប្រចាំ។ របាយការណ៍គណនីប្រាក់បញ្ញើ ដែលមានអាយុកាលយូរបាត់ម្ចាស់ និងគ្មានសកម្មភាពត្រូវបានរៀបចំដើម្បីពិនិត្យនិងបិទគណនីទាំងនោះ។ នៅក្នុងសកម្មភាពនៃការប្រមូលផ្តុំគណនីធនាគាររបស់រដ្ឋាភិបាល និងការពង្រឹងគណនីទោលរបស់រតនាគារនេះ ក្រសួង-ស្ថាប័នក៏បានចូលរួមក្នុងការពិនិត្យគណនី និងបានផ្តល់ព័ត៌មានពាក់ព័ន្ធគនទីដែលមាននៅក្នុងធនាគារជាតិ និងធនាគារពាណិជ្ជមកអគ្គនាយកដ្ឋានរតនាគារជាតិដែលជួយឱ្យកិច្ចការមានដំណើរទៅមុខ ប៉ុន្តែកិច្ចសហការនៅពុំទាន់បានពេញលេញពីគ្រប់ ក្រសួង-ស្ថាប័ននោះទេ។

ព្រមជាមួយនេះការប្រើប្រាស់សេវាធនាគារពាណិជ្ជនិងការជំរុញការបើកបៀវត្សតាមប្រព័ន្ធធនាគារត្រូវបានអនុវត្តបន្ត។ នៅក្នុងឆមាសទី១ ក្រសួង-ស្ថាប័ន ចំនួនត្រឹម ២១ (លើចំនួនសរុប ៣៨) បានប្រើប្រាស់សេវាធនាគារដើម្បីបើកប្រាក់បៀវត្ស។ មកដល់ខែធ្នូ ឆ្នាំ២០០៩ ក្រសួង-ស្ថាប័នប្រើប្រាស់សេវាធនាគារកើនដល់ចំនួន ២៦ ដោយឡែកក្រសួង-ស្ថាប័នចំនួន១០ បានបើកគណនីតែពុំទាន់បានប្រើប្រាស់ និងក្រសួង-ស្ថាប័នចំនួន ០២ មិនទាន់បានបើកគណនីនៅឡើយ។ នៅក្នុងការកែលម្អប្រតិបត្តិការគ្រប់គ្រងសាច់ប្រាក់ចំណូល-ចំណាយ សេវាធនាគារពាណិជ្ជអេស៊ីលីដាត្រូវបានដាក់អនុវត្តសាកល្បងនៅខេត្តចំនួន០២ ហើយការសិក្សាអំពីវិសាលភាពពង្រីកការប្រើប្រាស់ប្រព័ន្ធធនាគារនៅទីតាំងសំខាន់ៗ (ចំនួន ០៥បន្ថែមទៀតនៅក្នុងត្រីមាសទី ១ ឆ្នាំ ២០១០) និងនៅទូទាំងប្រទេសព្រមទាំងនីតិវិធីនៃការប្រើប្រាស់លិហូរសាច់ប្រាក់ឆ្លងកាត់ធនាគារកំពុងអនុវត្តបន្ត។ អគ្គនាយកដ្ឋានរតនាគារជាតិក៏បានចេញសេចក្តីណែនាំស្តីពីកិច្ចដំណើរការនៃប្រតិបត្តិការចំណូល-ចំណាយថវិកា ព្រមទាំងកិច្ចបញ្ជីកាចំណូល-ចំណាយលើកម្រៃការប្រាក់ដែលបានទទួលពីធនាគារអេស៊ីលីដាផងដែរ។ ក្នុងកិច្ចប្រឹងប្រែងនេះ ក្រសួង-ស្ថាប័នភាគច្រើនបានចូលរួមសហការកាត់បន្ថយចំនួនប្រតិបត្តិការដែលផ្អែកលើសាច់ប្រាក់និងពង្រីកការប្រើប្រាស់ប្រព័ន្ធធនាគារសម្រាប់ការបើកបៀវត្ស។

នៅក្នុងក្របខ័ណ្ឌការងារនៃការពង្រឹងការគ្រប់គ្រងសាច់ប្រាក់នេះដែរ ការងារមួយចំនួនត្រូវបាននិងកំពុងបន្តអនុវត្តមានដូចជា ការចងក្រងតារាងចំណាយ តារាងចំណូល (រួមទាំងចំណាយ-ចំណូលមូលធន) តាមក្រសួង តាមជំពូក តាមគណនី និងអនុគណនី ដោយបញ្ចូលទិន្នន័យឆ្នាំ ២០០៧ និង

២០០៨ និងធ្វើបច្ចុប្បន្នភាពទិន្នន័យប្រចាំខែសម្រាប់ឆ្នាំ២០០៩, របាយការណ៍សមតុល្យសាច់ប្រាក់ប្រចាំថ្ងៃ សប្តាហ៍ និងខែ តារាងគំរូព្យាករណ៍ប្រចាំខែ ការកំណត់ទម្រង់និងម៉ូដែលសម្រាប់ព្យាករណ៍លំហូរសាច់ប្រាក់ ការប្រៀបធៀបលំហូរសាច់ប្រាក់ជាក់ស្តែង និងការព្យាករណ៍ប្រចាំខែ កែតម្រូវការព្យាករណ៍ដោយផ្អែកលើស្ថានភាពចំណូល-ចំណាយជាក់ស្តែង និងព័ត៌មានពីនាយកដ្ឋានពាក់ព័ន្ធ ការរៀបចំ **RACI Matrix Template** សម្រាប់ប្រព័ន្ធព័ត៌មានវិទ្យា សិក្សាស្វែងរករូបមន្តដើម្បីកំណត់កម្រិតការពារសាច់ប្រាក់រដ្ឋាភិបាលនៅគណនីទោលរតនាគារជាតិ។ ក្នុងកិច្ចការនេះ ក្រសួង-ស្ថាប័នមួយចំនួនក៏បាននិងកំពុងរួមចំណែកយ៉ាងសកម្មដូចជាការផ្តល់ផែនការចំណូល-ចំណាយ និងតួលេខព្យាករណ៍ចំណូល-ចំណាយនិងរបាយការណ៍សមតុល្យលំហូរសាច់ប្រាក់ជាដើម។ ជាការគួរមានមោទនភាពនោះ គឺចាប់តាំងពីឆ្នាំ២០០៧ មក បំណុលកកស្ទះមិនមាននៅអគ្គនាយកដ្ឋានរតនាគារជាតិឡើយ។

បន្ថែមលើវឌ្ឍនភាពដែលសម្រេចបានខាងលើនេះ សកម្មភាពពង្រីកការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ប្រតិបត្តិការរតនាគារកំពុងត្រូវបានយកចិត្តទុកដាក់ជាប្រចាំ ដែលក្នុងនោះ ការសិក្សាអំពីតម្រូវការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យានៅតាមនាយកដ្ឋាននីមួយៗរបស់អគ្គនាយកដ្ឋានរតនាគារជាតិ បាន និងកំពុងដំណើរការ ដោយបានអនុវត្តសាកល្បងលើប្រតិបត្តិការផ្នែកចំណាយថវិកាដែលបានជំនួសការងារដោយដៃ។ ការសិក្សាវាយតម្លៃជាលក្ខណៈឯករាជ្យអំពីស្ថានភាពនៃការប្រើប្រាស់ប្រព័ន្ធ Conical Hat និងតម្រូវការនៃការដាក់ឱ្យដំណើរការប្រព័ន្ធស្វ័យប្រវត្តិកម្មនៅអគ្គនាយកដ្ឋានរតនគារជាតិត្រូវបានអនុវត្តរួចរាល់ ។ បណ្តាញ (Network) នៅអគ្គនាយកដ្ឋានរតនាគារជាតិ រួមទាំងរតនាគាររាជធានីភ្នំពេញត្រូវបានរៀបចំ និងដាក់ឱ្យដំណើរការ ព្រមជាមួយនេះ បណ្តាញ WiFi បានគ្របដណ្តប់បរិវេណអគារអគ្គនាយកដ្ឋានស្ទើរទាំងស្រុង ។ គេហទំព័រអគ្គនាយកដ្ឋានរតនគារជាតិ (www.treasury.gov.kh) ត្រូវបានបង្កើត និងដាក់ឱ្យដំណើរការ មជ្ឈមណ្ឌលឯកសាររបស់អគ្គនាយកដ្ឋានរតនាគារជាតិក៏ត្រូវបានបង្កើតផងដែរសម្រាប់ការប្រើប្រាស់ផ្ទៃក្នុង (ឯកសារទាញចេញពី Server)។

- **បន្តកែលម្អលទ្ធកម្មសាធារណៈ**

នៅក្នុងសកម្មភាពកែលម្អលទ្ធកម្មសាធារណៈ កិច្ចការមួយចំនួនត្រូវបានអនុវត្ត ដូចជា ការពិនិត្យកែលម្អបន្ថែមឧបសម្ព័ន្ធនៃ **IRRPP** ត្រូវបានបញ្ចប់ និងត្រៀមបោះពុម្ពផ្សាយ កែលម្អឯកសារដេញថ្លៃឱ្យស្របតាម **IRRPP** រៀបចំសេចក្តីណែនាំស្តីពីការកសាងផែនការលទ្ធកម្មឆ្នាំ២០១០ និងគំរូរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្ម, កែលម្អផែនការលទ្ធកម្មរបស់ក្រសួង-ស្ថាប័នចំណាយ, តាមដានការអនុវត្តផែនការលទ្ធកម្មរបស់ស្ថាប័នចំណាយ ប្រមូលនិងវិភាគរបាយការណ៍លទ្ធកម្មស្ថាប័នចំណាយ ធ្វើសវនកម្មកិច្ចលទ្ធកម្មជាក្រោយលើស្ថាប័នចំនួន ១៦ និងខេត្ត ២២ កែលម្អរចនាសម្ព័ន្ធនាយកដ្ឋានលទ្ធកម្មសាធា

រណៈរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការបង្កើតការិយាល័យផែនការលទ្ធកម្ម រៀបចំសេចក្តីព្រាងប្រកាសស្តីពីការបង្កើតសាខាលទ្ធកម្មរាជធានី និងខេត្ត ការវាយតម្លៃជ្រើសរើសទីប្រឹក្សាអន្តរជាតិដើម្បីរៀបចំសេចក្តីព្រាងច្បាប់លទ្ធកម្មកំពុងដំណើរការ, បានបញ្ជូនមន្ត្រីចំនួន០២រូបទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីលទ្ធកម្មអន្តរជាតិនៅសហរដ្ឋអាមេរិក, ជ្រើសរើសមន្ត្រីបន្ថែមដើម្បីបម្រើការងារនៅក្នុងនាយកដ្ឋានលទ្ធកម្ម និងរៀបចំវគ្គបណ្តុះបណ្តាលជំនាញលទ្ធកម្មដល់មន្ត្រីថ្មីក្នុងនាយកដ្ឋាន និងការងាររៀបចំគេហទំព័រលទ្ធកម្មកំពុងដំណើរការ។

ទន្ទឹមនេះ ក្រសួង-ស្ថាប័នមួយចំនួន ក៏បាន និងកំពុងធ្វើការកែលម្អផ្នែកលទ្ធកម្មសាធារណៈរបស់ខ្លួន ដោយបានបំពេញសកម្មភាពសំខាន់ៗមួយចំនួនដូចជា ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ ការរៀបចំកាលវិភាគអនុវត្តលទ្ធកម្ម និងកាលវិភាគតាមដានលទ្ធកម្មជាដើម។ ក្រសួង-ស្ថាប័ន ក៏បានបញ្ជូនមន្ត្រីជំនាញឱ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីលទ្ធកម្មដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, បានបញ្ជូនរបាយការណ៍និងទិន្នន័យលទ្ធកម្មមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងបានធ្វើការកែលម្អការប្រកួតប្រជែងក្នុងដំណើរការលទ្ធកម្ម តាមរយៈការផ្តល់ឯកសារនិងទិន្នន័យពាក់ព័ន្ធលទ្ធកម្មដល់អ្នកចូលរួម និងការផ្សព្វផ្សាយអំពីកិច្ចលទ្ធកម្មជាដើម។

## ២.២ សកម្មភាពជំហានទី ២ ដែលត្រូវអនុវត្តនៅក្នុងដំណាក់កាលទី២

នៅក្នុងដំណើរការឆ្ពោះទៅរកការសម្រេចឱ្យបាននូវការធ្វើឱ្យប្រសើរឡើងគណនេយ្យភាពហិរញ្ញវត្ថុដែលជាគោលបំណងចំបងយុទ្ធសាស្ត្រនៃជំហានទី ២នោះ ចង្កោមសកម្មភាពការងារត្រូវបានចងក្រងនៅជុំវិញគោលបំណងចំនួន០៨ ដែលជោគជ័យក្នុងគោលបំណងទាំងអស់នេះ នឹងបង្កើនគណនេយ្យភាពហិរញ្ញវត្ថុឱ្យកាន់តែប្រសើរឡើង។

### - កែលម្អបន្ទាត់គណនេយ្យភាពដោយកំណត់ឱ្យបានច្បាស់ពីតួនាទី មុខងារ និង ការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័ន គ្រប់កម្រិត និងរបស់អង្គភាពក្រោមឱវាទ

ការសិក្សាលើក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធនឹងការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពថវិកា ព្រមទាំងអ្នកគ្រប់គ្រងថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានចាប់ផ្តើមជាបណ្តើរៗ ដោយបានចាប់ផ្តើមពិនិត្យពីសង្គតិភាពរវាងអនុក្រឹត្យ ឯកសារបទបញ្ញត្តិផ្សេងៗដែលមានស្រាប់ គណនេយ្យភាពថ្មី អង្គភាពថវិកា ជាមួយនឹងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០០៨។ ការសិក្សាការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពថវិកា និងអ្នកគ្រប់គ្រងថវិកានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការស្រាវជ្រាវឯកសារពាក់ព័ន្ធទៅនឹងក្របខ័ណ្ឌទទួលខុសត្រូវដែលកំពុងអនុវត្តក្នុងការរៀបចំផែនការវិនិយោគសាធារណៈ

(PIP) កំពុងដំណើរការ។ គ្រប់ក្រសួង-ស្ថាប័ន ត្រូវបានស្នើឱ្យផ្ដល់នូវរចនាសម្ព័ន្ធដើម្បីមានជាមូលដ្ឋានក្នុងការពិនិត្យសិក្សា និងត្រៀមរៀបចំការកំណត់អង្គភាពថវិកា និងអ្នកគ្រប់គ្រងថវិកា។ ជាលទ្ធផលបឋម សេចក្ដីព្រាងដំបូងស្ដីពីការកំណត់អង្គភាពថវិកា និងអ្នកគ្រប់គ្រងថវិកា និងតារាងសម្រង់រចនាសម្ព័ន្ធក្រសួង-ស្ថាប័ន ត្រូវបានរៀបចំរួចហើយ ។ ក្រសួង-ស្ថាប័ន បាន និងកំពុងធ្វើការពិនិត្យ កែសម្រួលពង្រាងឯកសារកំណត់ពីការទទួលខុសត្រូវថវិកា រៀបចំ និងកែសម្រួលមន្ត្រីទទួលខុសត្រូវក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ធ្វើការបែងចែកឱ្យដាច់តួនាទី ភារកិច្ច របស់នាយកដ្ឋាន ឬការិយាល័យនីមួយៗដើម្បីឈានទៅកំណត់ការទទួលខុសត្រូវនៅក្នុងកម្រិតនីមួយៗ រៀបចំអ្នកគ្រប់គ្រងថវិកាថ្មី និងលំហូរថវិកា ស្របតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរៀបចំសាកល្បងដំណើរការក្របខ័ណ្ឌគណនេយ្យភាពថ្មីនៅតាមអង្គភាពក្រោមឱវាទនិងដំណើរការការងារថ្មី។ ក្រសួង-ស្ថាប័នមួយចំនួនក៏បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីសិទ្ធិអំណាច និងការទទួលខុសត្រូវរបស់អង្គភាពថវិកា និងបន្តការផ្សព្វផ្សាយអំពីការគ្រប់គ្រងថវិកាថ្មី និងលំហូរថវិកាថ្មី ការរៀបចំផែនការថវិកានៅក្នុងក្រសួង ការរៀបចំឱ្យមានគ្រូបង្គោល និងក៏បានចាប់ផ្ដើមធ្វើពង្រាងយន្តការ និងរៀបចំគំនូសបំព្រួញអំពីលំហូរថវិកាដែលកំពុងអនុវត្ត និងពង្រាងឯកសារពីតួនាទី និងការទទួលខុសត្រូវ។

ដំណើរការវិភាគមុខងារសម្រាប់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចាប់ផ្ដើមដោយបានស្នើឡើងនូវវិធីសាស្ត្រនៃការអនុវត្តវិភាគមុខងារ និងយុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្ស និងបានដាក់ឱ្យមានការពិភាក្សាពីគ្រប់អគ្គនាយកដ្ឋាន/នាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ដំណើរវិភាគមុខងារនេះ នឹងអនុវត្តដោយផ្សារភ្ជាប់ជាមួយអភិក្រមការងារថ្មីដែលកំពុងស្ថិតក្នុងដំណាក់កាលពិនិត្យកែលម្អក្រោមគម្រោង FMIS។

ដោយឡែកកិច្ចការពង្រាយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុកំពុងរៀបចំដើម្បីចាត់បញ្ជូនមន្ត្រីទៅប្រចាំនៅក្រសួង-ស្ថាប័នចំណាយចំនួន ១១ (ក្នុងឆ្នាំ ២០០៨ មានចំនួន ០៩នាក់) និងកំពុងត្រៀមរៀបចំពង្រាយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទៅតាមបណ្ដាក្រសួង-ស្ថាប័នបន្ថែមទៀត។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ក៏ត្រូវបានផ្ដល់សិទ្ធិអំណាចច្រើនថែមទៀតក្នុងដំណើរការនីតិវិធីចំណាយ។

### ~ កែលម្អឧបករណ៍ដែលជំរុញឱ្យមានការទទួលខុសត្រូវចំពោះការគ្រប់គ្រងហិរញ្ញវត្ថុនិងការពង្រឹងគណនេយ្យភាព

នៅក្នុងក្របខ័ណ្ឌនៃការកែលម្អប្រសិទ្ធភាពគ្រប់គ្រងហិរញ្ញវត្ថុ កិច្ចការមួយចំនួនត្រូវបានអនុវត្តក្នុងនោះមានការរៀបចំគោលការណ៍ណែនាំស្ដីពីនីតិវិធី និងបរិបទនៃការធានាចំណាយ និងការទូទាត់អាណត្តិបើកប្រាក់ ការផ្សព្វផ្សាយវិន័យ ១០ប្រការក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដល់ក្រសួង-ស្ថាប័ន មន្ទីររាជធានី-ខេត្ត និងសហគ្រាសសាធារណៈ ការរៀបចំសារាចរណែនាំការអនុវត្តចំណាយ ការធ្វើ

វិចារណកម្មចំណាយលើប្រាក់បៀវត្ស ប្រាក់លាភការ ប្រាក់បំណាច់មុខងាររបស់ទីប្រឹក្សា ការអនុវត្តវិធានការសៀតគៀតសន្សំសំចៃដើម្បីកាត់បន្ថយចំណាយដំណើរការរដ្ឋបាល ការរៀបចំចងក្រងមូលដ្ឋានទិន្នន័យគតិយុត្តពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុសាធារណៈ ការប្រមូលទិន្នន័យពាក់ព័ន្ធចំណាយដើម្បីធ្វើការវាយតម្លៃ។ ស្របជាមួយនេះ ថវិកាតាមកម្មវិធី ផែនការយុទ្ធសាស្ត្រថវិកា ប្រព័ន្ធរបាយការណ៍ពិនិត្យមើលសមិទ្ធកម្មនៃការប្រើប្រាស់ថវិកា ត្រូវបានកែលម្អនិងពង្រឹងបន្ថែម ដើម្បីប្រើជាឧបករណ៍សម្រាប់ការវិភាជន៍ថវិកា។ ដោយឡែក ក្រសួង-ស្ថាប័នមួយចំនួនក៏បាននិងកំពុងរៀបចំតារាងបទដ្ឋានត្រួតពិនិត្យការគ្រប់គ្រងហិរញ្ញវត្ថុ ផែនការចុះត្រួតពិនិត្យអង្គភាពក្រោមឱវាទនិងរបាយការណ៍ត្រួតពិនិត្យការគ្រប់គ្រងធនធានប្រចាំត្រីមាស។

## ~ បន្តកែលម្អការអនុវត្តមាតិកាថវិកាថ្មី និង ប្លង់គណនេយ្យថ្មី

សកម្មភាពដែលបានអនុវត្តដើម្បីឆ្លើយតបនឹងគោលបំណងខាងលើរួមមាន កែសម្រួលរចនាសម្ព័ន្ធនៃចំណាត់ថ្នាក់ថវិកាឱ្យសមស្របតាមស្ថានភាពកម្ពុជា និងឯកភាពលើរចនាសម្ព័ន្ធនៃចំណាត់ថ្នាក់ថវិកាដែលត្រូវរៀបចំកែលម្អរួមមាន: ចំណាត់ថ្នាក់រដ្ឋបាល ចំណាត់ថ្នាក់សេដ្ឋកិច្ច ចំណាត់ថ្នាក់ភូមិសាស្ត្រ ចំណាត់ថ្នាក់មុខងារ ចំណាត់ថ្នាក់កម្មវិធី និងប្រភពនៃហិរញ្ញប្បទាន បានធ្វើការពិនិត្យលក្ខណ:១០យ៉ាងរបស់ **COFOG** ដោយប្រៀបធៀបជាមួយចំណាត់ថ្នាក់មុខងារទាំង០៤ (រដ្ឋបាល ការពារជាតិ-សន្តិសុខ សង្គមកិច្ច និងសេដ្ឋកិច្ច) ការរៀបចំចំណាត់ថ្នាក់ថវិកាថ្មី ចំណាត់ថ្នាក់គណនីតាមមុខងារ និងតាមកម្មវិធី (ចំណាត់ថ្នាក់មុខងារអាចអនុវត្តទៅបានលុះត្រាតែ **FMIS** ដំណើរការ) ការពិនិត្យកែលម្អចំណាត់ថ្នាក់សេដ្ឋកិច្ចដោយបានរៀបចំជាពង្រាងមាតិកាចំណូល និងមាតិកាចំណាយជាអនុ-អនុគណនី បានរៀបចំឯកសារគោលការណ៍ណែនាំអំពីការប្រើប្រាស់ចំណាត់ថ្នាក់សេដ្ឋកិច្ច និងបានពិនិត្យរៀបចំដាក់បញ្ចូលក្នុងប្រព័ន្ធ **FMIS** ការបង្កើតលេខកូដសម្រាប់សំគាល់កម្មវិធីត្រូវបានកំពុងសិក្សាដើម្បីរៀបចំចំណាត់ថ្នាក់កម្មវិធី ការជ្រើសរើសវិធីសាស្ត្រថ្មីតាមជំនាញការបារាំង និង IMF សម្រាប់ការកត់ត្រាបំណុលប្រាក់ត្រូវសងតាមរបាយការណ៍នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ និងបានឯកភាពលើការកត់ត្រាដើម្បីឱ្យមានភាពស៊ីគ្នារវាងមាតិកាថវិកា និង មាតិកាគណនេយ្យសម្រាប់ចំណាយវិនិយោគផលហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ បញ្ឈប់ការកត់ត្រាចំណាយវិនិយោគតាមប្រភពឥណទាន និងប្រកាន់ការកត់ត្រា តាមចំណាត់ថ្នាក់សេដ្ឋកិច្ចដោយញែកចំណាយដែលមានចរិកជាចំណាយចរន្តពីគម្រោងវិនិយោគ (ហិរញ្ញប្បទានក្រៅប្រទេស) និងកត់ត្រាស្របតាមមាតិកាថ្មី ការបន្តធ្វើសមាហរណកម្មបំណុលត្រូវទារ និងបំណុលត្រូវសងជាមួយអង្គភាពពាក់ព័ន្ធទាំងក្នុង និងក្រៅរតនាគារដល់ខែសីហា ឆ្នាំ ២០០៩ ការបន្តប្រមូលទិន្នន័យដើម្បីកត់ត្រាបំណុលប្រាក់ខ្ចី និងបំណុលប្រាក់ត្រូវទារ ការអភិវឌ្ឍកិច្ចបញ្ជីកាគណនេយ្យ បានចេញសេចក្តីណែនាំអំពីការកំណត់ភារកិច្ច និងការទទួលខុសត្រូវរបស់នាយកដ្ឋាននីមួយៗលើការកត់ត្រាបំណុលការបន្ត

ចម្លងលេខកូដបន្ទុំគ្នា (**Bridging Table**) រវាងប្លង់គណនីថ្មី និង តារាង TOFE ចម្លងតួលេខពីតារាង តុល្យភាពចូលក្នុងតារាង TOFE ប្រចាំខែនីមួយៗសម្រាប់ឆ្នាំ ២០០៩ ការធ្វើបច្ចុប្បន្នភាព **TOFE** ឆ្នាំ ២០០៨ **TOFE** ខែ មករា-ខែសីហា ឆ្នាំ២០០៩ **GFS** ខែមករា-ខែសីហា ឆ្នាំ ២០០៩ ធ្វើការកែសម្រួល ការតភ្ជាប់មាតិកាគណនីថ្មីទៅក្នុងស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល ( **GFS** ) របាយការណ៍ **TOFE** ដល់ខែមិថុនា ឆ្នាំ២០០៩ ត្រូវបានរៀបចំដាក់ផ្សាយតាម **Website** ការចាប់ផ្តើមការអនុវត្តការរៀបចំសលាកប័ត្របង់ចំ ណូលថវិកាដាច់គ្នានូវប្រាក់ពន្ធ ឆ្នាំ២០០៩ និងចំណូលប្រាក់ពន្ធឆ្នាំមុនៗ ដើម្បីអនុវត្តមួយជំហានទៀត នូវគណនេយ្យបង្គរ ការពិនិត្យសិក្សាដើម្បីកែលម្អការងារថវិកា និងកែសម្រួលប្លង់គណនេយ្យឃុំ-សង្កាត់ ស្រុក-ខណ្ឌ-ក្រុង រាជធានី-ខេត្តកំពុងអនុវត្តបន្ត និងរៀបចំចងក្រងឯកសារពាក់ព័ន្ធនឹងការងាររតនាគារជាតិដើម្បីធ្វើការផ្សព្វផ្សាយដល់មន្ត្រីជំនាញ និងបានរៀបចំវគ្គបណ្តុះបណ្តាលចំនួន ០៣ លើក។

ក្រសួង-ស្ថាប័ន បាន និងកំពុងអនុវត្តជាបណ្តើរៗការកែលម្អប្លង់គណនេយ្យថ្មី ចំណាត់ថ្នាក់ថវិកាថ្មី ការរៀបចំអនុវត្តថវិកាផ្អែកតាមចំណាត់ថ្នាក់រដ្ឋបាល សេដ្ឋកិច្ច និង អនុមុខងារ រៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ ការចូលរួមធ្វើសង្គតិភាពរវាងចំណាត់ថ្នាក់នៃប្លង់គណនេយ្យថ្មី និង ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល ហើយបានប្រើប្រាស់មន្ត្រីដែលបានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលផ្នែកប្លង់គណនេយ្យថ្មីនិងចំណាត់ថ្នាក់ថវិកាថ្មីរៀបចំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបណ្តុះបណ្តាលបន្តដល់មន្ត្រីផ្សេងទៀតនិងរៀបចំផែនការបណ្តុះបណ្តាលលើការអនុវត្តចំណាត់ថ្នាក់ថវិកាថ្មី ។

### ~ កែលម្អដំណើរការ និងប្រតិបត្តិការអនុវត្តថវិកា

សកម្មភាពដែលបាន និងកំពុងអនុវត្តក្នុងផ្នែកនេះមានដូចជា ការអនុម័តអនុក្រឹត្យស្តីពីការកែលម្អនីតិវិធីចំណាយថវិកាចរន្ត និងចំណាយថវិកាវិនិយោគសម្រាប់ថវិកាបុរេប្រទាន បានចេញសារាចរណែនាំបន្ថែមស្តីពីកិច្ចបញ្ជីការរជ្ជទេយ្យបុរេប្រទាននៅតាមក្រសួង-ស្ថាប័ន មន្ទីររាជធានី-ខេត្តជាមួយរតនាគារខេត្ត-រាជធានី ការរៀបចំតាក់តែងឯកសារគណនេយ្យសម្រាប់តាមដានការកត់ត្រារជ្ជទេយ្យបុរេប្រទាន រជ្ជទេយ្យចំណូល និងបង្កើតតារាងតុល្យភាពគណនី សិក្សាបញ្ជិការគណនេយ្យដែលទាក់ទងនឹងថវិកាកម្មវិធី និងរជ្ជទេយ្យចំណូល រៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាផ្សព្វផ្សាយអំពីចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ នីតិវិធីចំណាយ និងកិច្ចបញ្ជិកាគណនេយ្យ នីតិវិធីចំណូល ចំណាយ-ចំណាយ និងវិធានគណនេយ្យ ការបន្តកាត់បន្ថយបរិបទការងារ និងពន្លឿនការពិនិត្យលិខិតយុត្តិការភ្ជាប់តាមអាណត្តិបើកប្រាក់ និងការទូទាត់ ការផ្ទៀងផ្ទាត់ប្រចាំខែរបាយការណ៍ចំណាយ និងតារាង

គុណភាពគណនី បានបញ្ឈប់ការចំណាយលើសលទ្ធភាពថវិកា និងកាត់បន្ថយឥណទានជាប់សន្យាចំណាយដែលជាបំណុលកកស្ទះបណ្តើរៗ។

ចំពោះការអនុវត្តគម្រោង FMIS ឯកសារដេញថ្លៃសម្រាប់ដំណាក់កាលទី២នៃគម្រោង FMIS ត្រូវបានបញ្ជូនដល់ធនាគារពិភពលោកជាលើកទី ៧ ដើម្បីទទួលការឯកភាព (NOL) បានបញ្ចប់ការភ្ជាប់នីតិវិធីអនុវត្តការងាររួមសម្រាប់ដំណើរការអនុវត្តការងារនីមួយៗពីចំណុចចាប់ផ្តើមរហូតដល់ចុងបញ្ចប់ (**End to End Current Process Mapping-From Procure to Pay**) និងបានសាកល្បងកំណត់អត្តសញ្ញាណនីតិវិធី ការងារយុទ្ធសាស្ត្រគ្រប់គ្រងការផ្លាស់ប្តូរ និងផែនការទំនាក់ទំនងត្រូវបានចាប់ផ្តើមដាក់អនុវត្ត ព្រមទាំងបានធ្វើការអង្កេតចំនួនពីរលើកអំពីការយល់ដឹងគម្រោង FMIS និងការផ្លាស់ប្តូរសម្រាប់គម្រោង និងរៀបចំទស្សនកិច្ចក្រោមគម្រោង FMIS នៅ Tanzania និង Uganda ។

ក្រសួង-ស្ថាប័ន បាន និងកំពុងបន្តរៀបចំការកាត់បន្ថយភាពស្មុគ្រស្មាញផ្ទៃក្នុងសម្រាប់ការស្នើសុំឥណទាន ធ្វើការកែលម្អប្រតិបត្តិការធានាចំណាយ និងការទូទាត់ដោយរៀបចំឱ្យមានសេម៉ាដំណើរការរៀបចំតារាងតាមដាន និងត្រួតពិនិត្យពេលវេលានៃការស្នើសុំធានាចំណាយ ធ្វើការត្រួតពិនិត្យការកត់ត្រាអាណត្តិ ឬបុរេប្រទានឱ្យស្របតាមវិធានគណនេយ្យ និងប្លង់គណនេយ្យថ្មី។

## ~ កែលម្អប្រព័ន្ធគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុដើម្បីធានាគណនេយ្យភាព

សកម្មភាពដែលបានអនុវត្តមានដូចជា ការកែលម្អ និងជំរុញឱ្យអនុវត្តមាតិកាប្លង់គណនេយ្យថ្មី ណែនាំអំពីការកត់ត្រាបំណុលពន្ធតាមរបៀបជាប្រចាំ ការរៀបចំសេចក្តីព្រាងប្រកាសបង្កើតបន្ថែមគណនីប្រាក់បញ្ញើនៅធនាគារពាណិជ្ជ គណនីមូលនិធិស្រុក-ខណ្ឌ គណនីប្រាក់បញ្ញើរបស់ស្រុក ខណ្ឌ គណនីប្រាក់បញ្ញើថវិកាស្រុក ខណ្ឌនៅរតនាគារខេត្ត គណនីចរន្តនៅធនាគារពាណិជ្ជ ដាក់អនុវត្តសេចក្តីណែនាំស្តីពីកិច្ចបញ្ជិកាចំណូលការប្រាក់ពីគណនីចរន្តសម្រាប់ចំណូល-ចំណាយឃុំ-សង្កាត់នៅធនាគារអេស៊ីលីដា រៀបចំសេចក្តីព្រាងប្រកាសណែនាំស្តីពីការអនុវត្តប្រតិបត្តិការចំណូល-ចំណាយជាមួយធនាគារពាណិជ្ជអេស៊ីលីដា រៀបចំវគ្គបណ្តុះបណ្តាលកិច្ចបញ្ជីការជ្ជទេយ្យបុរេប្រទាន រជ្ជទេយ្យចំណូលដល់ក្រសួង-ស្ថាប័ន សេចក្តីណែនាំស្តីពីការអនុវត្តកិច្ចប្រតិបត្តិការនៅធនាគារពាណិជ្ជ ការសិក្សាលើការកាន់គណនេយ្យថ្នាក់ក្រោមជាតិ កិច្ចបញ្ជីកាបំណុលអចលនទ្រព្យទាក់ទងនឹងចំណាយវិនិយោគ ការប្រើប្រាស់ប្រព័ន្ធ **DMFAS** ដើម្បីធ្វើឱ្យមានស្វ័យប្រវត្តិកម្មប្រព័ន្ធរបាយការណ៍របស់ការិយាល័យគ្រប់គ្រងបំណុលតាមរយៈប្រព័ន្ធព័ត៌មានវិទ្យា ការរៀបចំ Process online នៅនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការកំពុងដំណើរការ គំរូរបាយការណ៍សមិទ្ធកម្មនៃការអនុវត្តថវិកាប្រចាំត្រីមាសប្រចាំឆមាស និងប្រចាំឆ្នាំ ត្រូវបានរៀបចំឡើង ហើយបានដាក់ឱ្យមានការពិភាក្សាជាមួយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំបោះពុម្ពផ្សព្វផ្សាយព្រឹត្តប័ត្រ

ព័ត៌មានអំពីពន្ធលើអាករបន្ថែម (VAT) និងសៀវភៅជំនួយស្មារតីស្តីពីសិទ្ធិ និងកាតព្វកិច្ចអ្នកជាប់ពន្ធ និងរៀបចំសៀវភៅណែនាំជំនួយស្មារតីអំពីប្រភេទពន្ធផ្សេងៗ ការសិក្សាលើការបញ្ចូលគ្នារវាងប្លង់គណនេយ្យរដ្ឋ ប្លង់គណនេយ្យថវិកាខេត្ត ប្លង់ គណនេយ្យថវិកាស្រុក និងប្លង់គណនេយ្យថវិកាឃុំ-សង្កាត់ ឱ្យមានប្លង់គណនេយ្យតែមួយដើម្បីដាក់បញ្ចូលក្នុង FMIS កំពុងមានដំណើរការ និងរបាយការណ៍ TOFE ត្រូវបានរៀបចំផ្សាយតាមគេហទំព័រក្រសួង។ ចំពោះការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ការរៀបចំធ្វើប័ណ្ណកម្មសិទ្ធិទ្រព្យសម្បត្តិរដ្ឋកំពុងមានដំណើរការ ព្រមជាមួយការរៀបចំសៀវភៅណែនាំស្តីពីការរៀបចំបញ្ជីសារពើភ័ណ្ឌនិងលក្ខខណ្ឌការងារសម្រាប់ក្រុមហ៊ុនសិក្សាវាយតម្លៃតម្រូវការប្រព័ន្ធទិន្នន័យទ្រព្យសម្បត្តិរដ្ឋដោយប្រព័ន្ធកុំព្យូទ័រ ការធ្វើបញ្ជីសារពើភ័ណ្ឌឆ្នាំ ២០០៩ បានកំពុងអនុវត្ត និងបានជំរុញការវាយតម្លៃដី និងអគារសាធារណៈ និងការផ្ទេរផ្គងទ្រព្យសម្បត្តិរដ្ឋកើនឡើង-ថយចុះ ឆ្នាំ២០០៨។

ក្រសួង-ស្ថាប័ន បាន និងកំពុងប្រមូលចងក្រងគំរូរបាយការណ៍គណនេយ្យ រៀបចំរបាយការណ៍ផ្ទៃក្នុង រៀបចំរបាយការណ៍តាមគំរូរបាយការណ៍ថ្មីដែលឆ្លើយតបនឹងតម្រូវការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កែលម្អការកត់ត្រារបាយការណ៍ និងការត្រួតពិនិត្យទ្រព្យសម្បត្តិរដ្ឋជាប្រចាំ ព្រមទាំងការជំរុញការរៀបចំប័ណ្ណកម្មសិទ្ធិសំគាល់ទ្រព្យសម្បត្តិរដ្ឋនៅតាមបណ្តាអង្គភាពចំណុះក្រសួង-ស្ថាប័ន។

### កែលម្អសវនកម្ម និងអធិការកិច្ច ព្រមទាំងឆ្លើយតបទៅនឹងការប្រើប្រាស់លទ្ធផលនៃរបាយការណ៍សវនកម្ម និង អធិការកិច្ច

សកម្មភាពដែលបានអនុវត្តរួមមាន ការត្រួតពិនិត្យ និងតាមដានការបង្កើត និងដំណើរការរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រសួង-ស្ថាប័ន ជាលទ្ធផលក្រសួង ២៦ បានបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង ដែលក្នុងនោះ ក្រសួងចំនួន ១៨ (មានត្រឹម ១៣ នៅក្នុងឆមាស ទី ១) មានដំណើរការ សហគ្រាសសាធារណៈចំនួន ០៣ បានបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង និងកំពុងដំណើរការ កម្រងសំណួរពាក់ព័ន្ធនឹងស្ថានភាពសវនកម្មផ្ទៃក្នុងត្រូវបានផ្ញើទៅក្រសួងចំនួន ២៥ បានដំឡើងប្រអប់សំបុត្រសវនកម្មនៅរាជធានី-ខេត្តចំនួន ២៤ រៀបចំសិក្ខាសាលាស្តីពីផែនការយុទ្ធសាស្ត្រសវនកម្ម រៀបចំសេចក្តីព្រាងនីតិវិធីសវនកម្មផ្ទៃក្នុងសម្រាប់ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ដោយទើបសម្រេចបាននៅសាខាគយ និងរដ្ឋាករខេត្តព្រះសីហនុ និងស្នាក់ការគយ និងរដ្ឋាករប៉ោយប៉ែត អគ្គនាយកដ្ឋានពន្ធដារ និងបណ្តាសាខាក្រោមចំណុះដោយសម្រេចបាននៅនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ សៀវភៅណែនាំនីតិវិធីសវនកម្មកំពុងត្រូវរៀបចំជាបណ្តើរៗ បានរៀបចំផែនការសវនកម្មប្រចាំឆ្នាំ ២០០៩ និងផែនការសវនកម្ម០៣ឆ្នាំរំកិល ២០០៩-២០១១ និងកំពុងរៀបចំផែនការសវនកម្មប្រចាំឆ្នាំ ២០១០ និងផែនការយុទ្ធសាស្ត្រសវនកម្ម (០៣ឆ្នាំ) តាមនីតិវិធីថ្មី រៀបចំរួចរាល់ផែនការការងារអធិការកិច្ចរបស់អគ្គាធិការដ្ឋានសម្រាប់រយៈពេល

០៣ឆ្នាំ (២០០៩-២០១១) ពិនិត្យលើការបែងចែកតួនាទីនិងភារកិច្ចរវាងអធិការកិច្ច និងសវនកម្មផ្ទៃក្នុងនៅតាមបណ្តាក្រសួង-ស្ថាប័ន រៀបចំសេចក្តីព្រាងប្រកាសស្តីពីវិន័យក្រមសីលធម៌ និងការទទួលខុសត្រូវវិជ្ជាជីវៈសម្រាប់មន្ត្រីអធិការកិច្ចហិរញ្ញវត្ថុ វាយតម្លៃលើវិន័យ សកម្មភាពការងារនិងលទ្ធផលការងាររបស់មន្ត្រីអធិការកិច្ចហិរញ្ញវត្ថុ ពិនិត្យកែសម្រួលខ្លឹមសារសៀវភៅណែនាំស្តីពីនីតិវិធីនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុ រៀបចំនិងស្នើវគ្គបណ្តុះបណ្តាលមន្ត្រីអធិការកិច្ចហិរញ្ញវត្ថុព្រមទាំងការបន្តកិច្ចសហការជាមួយផ្នែកអធិការកិច្ចហិរញ្ញវត្ថុប្រទេសបារាំងដើម្បីទទួលបទពិសោធន៍ និងចំណេះដឹងបន្ថែម ។

ក្រសួង-ស្ថាប័ន បាននិងកំពុងរៀបចំឱ្យដំណើរការនាយកដ្ឋានសវនកម្មផ្ទៃក្នុង រៀបចំផែនការសវនកម្មប្រចាំឆ្នាំដោយបានសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កែលម្អយន្តការដើម្បីធានាឱ្យមានការឆ្លើយតបប្រកបដោយប្រសិទ្ធភាពជាមួយនឹងលទ្ធផលសវនកម្ម និងរៀបចំបញ្ជីសំណួរ និងលក្ខណៈវិនិច្ឆ័យចាំបាច់សម្រាប់ការងារសវនកម្ម។

## ~ ពង្រឹង និងរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រវិមជ្ឈការហិរញ្ញវត្ថុ

នៅក្នុងខណ្ឌការងារនេះ កិច្ចការសំខាន់ៗមួយចំនួនត្រូវបានអនុវត្តជាហូរហែ ដូចជាការពង្រឹងប្រព័ន្ធប្រតិបត្តិការ និងការរៀបចំថវិកាឱ្យស្របតាមច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ តាមរយៈការចេញសារាចរណែនាំការអនុវត្តថវិការាជធានី ខេត្តឆ្នាំ ២០០៩ សារាចរស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិការាជធានី ខេត្តឆ្នាំ ២០០៩ រៀបចំលក្ខខណ្ឌការងាររបស់ការិយាល័យហិរញ្ញវត្ថុមូលដ្ឋានថ្មីនៅតាមមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សិក្សាអំពីជម្រើសនីតិវិធីថវិកាស្វយ័ត និងថវិកាឯកភាពនៅតាមរាជធានី-ខេត្ត បានបង្កើតក្រុមការងារ និងតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការអនុវត្តថវិកាឃុំ-សង្កាត់ត្រូវបានកែសម្រួល រៀបចំសិក្ខាសាលាអំពីការអនុវត្តថវិកាឃុំ-សង្កាត់ រៀបចំសេចក្តីណែនាំដើម្បីកែលម្អកិច្ចលទ្ធកម្មសម្រាប់គម្រោងរបស់ថវិកាឃុំ សង្កាត់ សៀវភៅណែនាំអំពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ យុទ្ធសាស្ត្រចំណូលមិនមែនពន្ធនៅតាមរាជធានី-ខេត្តត្រូវបានកែលម្អឱ្យស៊ីសង្វាក់ជាមួយការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងសេចក្តីព្រាងច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការរៀបចំសេចក្តីព្រាងបែងចែកចំណូលទៅរដ្ឋបាលថ្នាក់ក្រោមជាតិកំពុងដំណើរការ ហើយប្លង់គណនេយ្យថ្មីសម្រាប់ថវិកាឃុំសង្កាត់ត្រូវបានធ្វើការពិនិត្យ និងកែលម្អ រៀបចំយុទ្ធសាស្ត្ររយៈពេលខ្លីសម្រាប់ការអនុវត្តវិមជ្ឈការសារពើពន្ធ (២០០៩-២០១១) និងយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់ការអនុវត្តវិមជ្ឈការសារពើពន្ធ (២០១១-២០១៨)។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចូលរួមកែលម្អនិងផ្តល់ធាតុចូលសម្រាប់ការរៀបចំសេចក្តីព្រាងកម្មវិធីជាតិរយៈពេល ១០ឆ្នាំ សម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ។ ក្រសួង-ស្ថាប័នបាននិងកំពុងអនុវត្តវិសហមជ្ឈការ

ដោយការផ្ទេរសិទ្ធិអាណាប័កពីថ្នាក់កណ្តាលឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិជាបណ្តើរៗ ប៉ុន្តែនៅមានចំនួនតិចតួចនៅឡើយ។

**- ការកសាងសមត្ថភាពស្ថាប័ន និង វិធានការលើកទឹកចិត្ត**

ក្រសួងកំពុងរៀបចំឯកសារគម្រោងបណ្តុះបណ្តាលកសាងជំនាញឯកទេសដើម្បីឱ្យមានស្តង់ដារមួយជាក់លាក់ (កម្មវិធី ២៣ មុខជំនាញ) សកម្មភាពបណ្តុះបណ្តាល និងសិក្ខាសាលាជាច្រើនត្រូវបានរៀបចំឡើង ដូចជាកម្មវិធីបណ្តុះបណ្តាលចំនួន០៣វគ្គស្តីពី "ភាពជាអ្នកដឹកនាំសម្រាប់ការគ្រប់គ្រងគោលនយោបាយសាធារណៈ" មានសិក្ខាកាមចូលរួមសរុបចំនួន ៨៨ នាក់ វគ្គបណ្តុះបណ្តាលលើមុខជំនាញស្តង់ដារគណនេយ្យកម្ពុជា មានសិក្ខាកាមចំនួន ៤៧ នាក់ វគ្គបណ្តុះបណ្តាលជំនាញលទ្ធកម្មសាធារណៈមានសិក្ខាកាមចំនួន ២៣ នាក់ សិក្ខាកាមចំនួន៥៣៩ នាក់បានទទួលការបណ្តុះបណ្តាលលើជំនាញចំនួន ០៩ ដែលមានបីកម្រិត (ផ្នែកគណនេយ្យ លទ្ធកម្ម គ្រប់គ្រង កុំព្យូទ័រ ភាសាអង់គ្លេស ថវិកា រតនាគារ និងការស្វែងយល់ពី កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ) សិក្ខាកាមដែលបានចូលរួមវគ្គបណ្តុះបណ្តាលខ្លីៗ មានចំនួនប្រមាណ ៨០០០ នាក់ សិក្ខាសាលាផ្សព្វផ្សាយមានអ្នកចូលរួមចំនួនសរុប ៤០០០ នាក់ បណ្តុះបណ្តាលគ្រូបង្គោលនៅអាជ្ញាធរសវនកម្មជាតិចំនួន ៤៣ នាក់ បានជ្រើសរើសនិស្សិតសរុបចំនួន ០៩រូបទៅសិក្សាក្រៅប្រទេសក្រោមអាហារូបករណ៍របស់កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានកែលម្អយន្តការតាមដាន និងត្រួតពិនិត្យវឌ្ឍនភាពនៃការសិក្សារបស់និស្សិត និងគោលនយោបាយ និងទម្រង់បច្ចេកទេសសម្រាប់ការជ្រើសរើសនិស្សិតទទួលអាហារូបករណ៍ រៀបចំកម្មវិធីសម្រាប់វគ្គបណ្តុះបណ្តាល ០៨ថ្នាក់ រៀបចំកម្មវិធីស្ម័គ្រចិត្តសម្រាប់អភិវឌ្ឍផែនការសកម្មភាពការផ្តល់សេវាប្រឹក្សាយោបល់ដល់ក្រសួងសុខាភិបាល ក្នុងការរៀបចំផែនការស្តីពីការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការបើកវគ្គបណ្តុះបណ្តាលអំពីការព្យាករណ៍ចំណូល សិក្ខាសាលាស្តីពីការគ្រប់គ្រងការផ្លាស់ប្តូរនិងពង្រឹងសមត្ថភាពព័ត៌មានវិទ្យា វគ្គសិក្សាភាសាអង់គ្លេស ការរៀបចំវិបស្សនាដើម្បីពិភាក្សាការកសាងផែនការសកម្មភាពដើម្បីអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន រៀបចំវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានចំនួនពីរកម្រិត បានបញ្ជូនមន្ត្រីជំនាញចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេសអំពីពន្ធ ផ្នែកគ្រប់គ្រងអចលនវត្ថុ ប្រេង និងឧស្ម័ន មន្ត្រីគយទទួលការបណ្តុះបណ្តាលក្នុងស្រុកលើជំនាញផ្នែកគយចំនួន ២៨ វគ្គ និងវគ្គក្រៅប្រទេសចំនួន ១២វគ្គ មន្ត្រីទទួលបន្ទុកការងារ FMIS ត្រូវបានទទួលការបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេស ហើយវគ្គបណ្តុះបណ្តាលអំពីគម្រោង FMIS ត្រូវបានរៀបចំសម្រាប់មន្ត្រីពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន និងវគ្គបណ្តុះបណ្តាលការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យានៅខេត្តចំនួន ០៦ ។

នៅក្នុងក្របខ័ណ្ឌនៃការងារគ្រប់ធនធានមនុស្ស សកម្មភាពអនុវត្តមានដូចជា ការធ្វើបច្ចុប្បន្នភាពទិន្នន័យបុគ្គលិក មន្ត្រីរាជការ ការរៀបចំសំណុំឯកសារផ្ទាល់ខ្លួនរបស់មន្ត្រីរាជការ ការចងក្រងច្បាប់និងបទបញ្ញត្តិគ្រប់គ្រងមុខងារសាធារណៈ ឯកសារពាក់ព័ន្ធបេសកកម្ម តួនាទី ភារកិច្ច រចនាសម្ព័ន្ធរបស់ក្រសួង និងអង្គភាពចំណុះ ត្រូវបានបញ្ចប់ និងបានរៀបចំឯកសារសម្រាប់ដេញថ្លៃបោះពុម្ពផ្សព្វផ្សាយ ។ ការវាយតម្លៃឯរាជ្យការអនុវត្តគម្រោង MBPI ត្រូវបានអនុវត្ត និងបានដាក់ចេញកញ្ចប់ MBPI និងកំណត់លក្ខណៈវិនិច្ឆ័យការបែងចែកចំនួនដល់បណ្ដាអង្គភាព និងក្រសួង-ស្ថាប័ន បានបញ្ចប់ការរៀបចំឯកសារសម្រាប់ការអនុវត្តប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធការងារ (ឯកសារគម្រោង ឯកសារណែនាំអំពីការអនុវត្ត MBPI ឯកសារស្ដីពីប្រព័ន្ធគ្រប់គ្រងប្រសិទ្ធភាពការងារ អនុស្សរណៈយោគយល់សម្រាប់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន ) ការផ្សព្វផ្សាយអំពីការរៀបចំឯកសារពាក់ព័ន្ធនឹងការអនុវត្តប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ (កិច្ចសន្យាការងារ លក្ខខណ្ឌការងារ កិច្ចព្រមព្រៀងសមិទ្ធកម្មប្រចាំឆ្នាំ ពាក្យស្នើសុំបម្រើការងារ លក្ខខណ្ឌនៃការតែងតាំង) ដល់អង្គភាពចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន (គម្រោង MBPI ត្រូវបានរាជរដ្ឋាភិបាល សម្រេចបញ្ចប់ចាប់ពីខែមករា ឆ្នាំ ២០១០)។ ទន្ទឹមនេះ ការងារប្រមូលទិន្នន័យមន្ត្រីរាជការ និងសិក្សាស្វែងយល់អំពីតម្រូវការកសាងសមត្ថភាពមន្ត្រីរាជការនៅតាមមន្ទីររាជធានីខេត្តត្រូវបានអនុវត្តចប់សព្វគ្រប់ និងកំពុងចាប់ផ្ដើមដំណើរការប្រមូលទិន្នន័យមន្ត្រីរាជការនៅរដ្ឋបាលកណ្ដាល និងនៅតាមបណ្ដាអគ្គនាយកដ្ឋាន។ ការជ្រើសរើសទីប្រឹក្សាសម្រាប់គម្រោងគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យាកំពុងដំណើរការព្រមជាមួយការដេញថ្លៃផ្គត់ផ្គង់គ្រឿងសម្ភារៈ Server ផ្ទាំងផ្សព្វផ្សាយព័ត៌មាននៅក្នុងក្រសួងចំនួន ០៤ ត្រូវរៀបចំដំឡើង កម្មវិធីសិក្សាលើប្រធានបទចំនួន ០៤ អំពីការគ្រប់គ្រងធនធានមនុស្ស ត្រូវបានផ្ដល់ដោយទីប្រឹក្សាអន្តរជាតិ បន្ថែមលើនេះសេចក្ដីព្រាងគោលនយោបាយ និងយុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្សក៏ត្រូវបានរៀបចំចេញជារូបរាងផងដែរ។

ក្រៅពីសកម្មភាពខាងលើនេះ នៅមានសកម្មភាពមួយចំនួនទៀតដែលបាននិងកំពុងអនុវត្ត រួមមានការរៀបចំតារាងប្រៀបធៀបបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋនៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្តចំនួន១៩ និងនៅតាមបណ្ដាអង្គភាពចំណុះក្រសួងមួយចំនួន ព្រមទាំងការជិះបញ្ជីសារពើភ័ណ្ឌ និងការចាប់ផ្ដើមរៀបចំបណ្ណាល័យ បន្ទប់សិក្សា និងកន្លែងដឹកល់ឯកសាររបស់សវនកម្ម។ ក្រសួង-ស្ថាប័ន បាននិងកំពុងរៀបចំផែនការបណ្ដុះបណ្ដាល និងជ្រើសរើសមន្ត្រីដែលមានសមត្ថភាព រៀបចំការបែងចែកមុខងារ និងភារកិច្ចសម្រាប់មន្ត្រីអនុវត្តការ ងារកែទម្រង់និងបានបញ្ជូនមន្ត្រីដើម្បីចូលរួមវគ្គបណ្ដុះបណ្ដាល និងសិក្ខាសាលាទាំងឡាយដែលបានរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ២.៣ សកម្មភាពសម្រាប់ជំហានបន្ទាប់ដែលត្រូវចាប់ផ្តើមជាបណ្តើរៗ

វឌ្ឍនភាពនៃសកម្មភាពជំហានបន្ទាប់ គឺមានគោលបំណងកែលម្អ និងពង្រីកការអនុវត្តថវិកាតាមកម្មវិធី ព្រមទាំងកែលម្អភាពគ្រប់ជ្រុងជ្រោយ និងសមាហរណកម្មនៃថវិកា។

### ‐ការកែលម្អ និងការពង្រីកការអនុវត្តថវិកាតាមកម្មវិធី

ដើម្បីរួមចំណែកដល់ការកែលម្អ និងការពង្រឹងការអនុវត្តថវិកាតាមកម្មវិធី គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាតាមកម្មវិធីត្រូវបានធ្វើការកែលម្អជាបន្តបន្ទាប់ និងផ្សព្វផ្សាយដល់មន្ត្រីទទួលបន្ទុកនៅក្នុងគ្រប់ក្រសួង-ស្ថាប័ន កែលម្អការរៀបចំបទដ្ឋានវាយតម្លៃលើគុណភាពនៃការរៀបចំថវិកាកម្មវិធី បានរៀបចំ និងដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំ និងគំរូរបាយការណ៍តាមដានវាយតម្លៃគម្រោង កែលម្អសកម្មភាព សូចនាករព្រមទាំងលទ្ធផលសម្រេចបានក្នុងឆ្នាំ និងលទ្ធផលចុងក្រោយ ដើម្បីឱ្យស្របតាមអនុកម្មវិធី និងកម្មវិធី កែលម្អ និងកំណត់ទិសដៅអនាគតលើការអនុវត្តតាមកម្មវិធី រៀបចំនីតិវិធីផ្ទៃក្នុងដើម្បីអនុវត្តសាកល្បងថវិកាតាមកម្មវិធី បង្កើតយន្តការផ្ទៃក្នុងដើម្បីរាយកាណ៍អំពីការអនុវត្តថវិកាតាមកម្មវិធី។ គោលការណ៍ណែនាំត្រូវបានត្រួតពិនិត្យជាប្រចាំសម្រាប់ការអនុវត្តសាកល្បងនៅក្រសួងទាំង ០៨ ។ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ទាំង២៤ បានបន្តសាកល្បងថវិកាកម្មវិធីក្រោមការពិនិត្យផ្ទាល់ពីក្រសួងអប់រំ យុវជន និងកីឡា។ ក្រសួង-ស្ថាប័ន ក៏បានរួមចំណែកក្នុងការផ្តល់មតិយោបល់លើការរៀបចំយុទ្ធសាស្ត្រនិងលក្ខណៈវិនិច្ឆ័យដើម្បីកំណត់ពីភាពគ្រប់គ្រាន់និងពេលវេលានៃការពង្រីកការសាកល្បងថវិកាតាមកម្មវិធី ហើយក៏បានធ្វើការកែលម្អផែនការយុទ្ធសាស្ត្ររបស់ខ្លួនដោយកំណត់កម្មវិធីការងារសាកល្បងកសាង និងអនុវត្តថវិកាតាមកម្មវិធី។ នៅក្នុងក្របខ័ណ្ឌនៃការពង្រឹងសមត្ថភាពមន្ត្រីរបស់ខ្លួនលើផ្នែករៀបចំ និងអនុវត្តថវិកាកម្មវិធី ក្រសួង-ស្ថាប័នបានរៀបចំជាផែនការបណ្តុះបណ្តាលផ្ទៃក្នុង និងបានប្រើប្រាស់ធនធានមនុស្សដែលទទួលការបណ្តុះបណ្តាលពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានបទពិសោធន៍លើការងារថវិកាកម្មវិធីដើម្បីផ្តល់ការបណ្តុះបណ្តាលបន្តដល់មន្ត្រីនៅរដ្ឋបាលកណ្តាល និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

### ‐ បន្តកែលម្អភាពគ្រប់ជ្រុងជ្រោយ និង ការធ្វើសមាហរណកម្មថវិកា

ក្នុងន័យបន្តកែលម្អភាពគ្រប់ជ្រុងជ្រោយ និងការធ្វើសមាហរណកម្មថវិកា ផែនការយុទ្ធសាស្ត្រថវិកាត្រូវបានបន្តពង្រឹងបន្ថែម ព្រមជាមួយនេះគោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាត្រូវបានធ្វើការកែសម្រួលជាចុងក្រោយ និងត្រៀមផ្សព្វផ្សាយដល់គ្រប់ក្រសួង-ស្ថាប័ន។ ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១០ របស់ក្រសួង-ស្ថាប័ន ត្រូវបានយកមកប្រើប្រាស់ដើម្បីធ្វើជាមូលដ្ឋានក្នុងការរៀបចំ

សារាចរណែនាំបច្ចេកទេសលើការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងប្រចាំឆ្នាំ២០១០។ ក្រសួងបានរៀបចំការព្យាករណ៍ឥណទានថវិកាគម្រោងវិនិយោគផ្ទាល់ "ជំពូក ២១ " ក្នុងក្របខ័ណ្ឌការអនុវត្តថវិការយៈពេលមធ្យម។ កិច្ចការមួយចំនួន ក៏កំពុងតែដំណើរការដូចជា ការប្រមូលព័ត៌មាន និងឯកសារស្តីពីចំណូល-ចំណាយរបស់សហគ្រាសពាណិជ្ជ និងឧស្សាហកម្ម ថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងថវិកាក្រៅបរិបថរបស់ដៃគូអភិវឌ្ឍន៍នៅគ្រប់ក្រសួង-ស្ថាប័ន ការកែលម្អគុណភាពនៃការផ្តល់ព័ត៌មានអំពីចំណាយមូលធនហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ដើម្បីធ្វើសមាហរណកម្មទៅក្នុងផែនការយុទ្ធសាស្រ្តថវិកា និងរបាយការណ៍ថវិកា ស្របជាមួយនេះ ការមានពិនិត្យផ្ទៀងផ្ទាត់គម្រោងវិនិយោគសាធារណៈ ជាមួយការរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ ២០១០-២០១២ និង ណែនាំឱ្យមានការបញ្ចូលក្នុងផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០១០-២០១២ នូវចំណូល-ចំណាយរបស់សហគ្រាសពាណិជ្ជនិងឧស្សាហកម្ម ថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងថវិកាក្រៅបរិបថរបស់ដៃគូអភិវឌ្ឍន៍។ក្រុមការងារទទួលបន្ទុកបានប្រមូលបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងដំណើរការរបស់គ្រឹះស្ថានសាធារណៈដើម្បីរៀបចំថវិកាឧបសម្ព័ន្ធហើយធ្វើសមាហរណកម្មទៅក្នុងថវិកាប្រចាំឆ្នាំនិងរៀបចំសារាចរណែនាំបច្ចេកទេស។ ក្រសួង-ស្ថាប័នដែលបានបង្ហាញខ្ទង់ចំណូល-ចំណាយរបស់ដៃគូអភិវឌ្ឍន៍ក្រៅបរិបថថវិកានៅមានចំនួនតិចតួចនៅឡើយ។ សេចក្តីព្រាងរបាយការណ៍ស្តីពីការអនុវត្តថវិកាក្រៅបរិបថថវិកាត្រូវបានរៀបចំឡើង។

ទន្ទឹមនេះ ការធ្វើបច្ចុប្បន្នភាពក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ២០១១-២០១៣ កំពុងអនុវត្តជាបន្ត និងក៏បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ២០១០-២០១២ ដល់ក្រសួង-ស្ថាប័នផងដែរ។ ក្រសួង-ស្ថាប័នបាន និងកំពុងកែលម្អជាបណ្តើរៗការរៀបចំផែនការយុទ្ធសាស្រ្តថវិកា ដោយបានបង្កើត និងជំរុញឱ្យដំណើរការក្រុមការងារផែនការយុទ្ធសាស្រ្តថវិកា ផ្សព្វផ្សាយដល់អង្គភាពក្រោមឱវាទអំពីការរៀបចំផែនការយុទ្ធសាស្រ្តថវិកា ដំណើរការនៃការធ្វើសមាហរណកម្មទៅក្នុងថវិការួមរបស់ក្រសួង ការសម្របសម្រួលនៅក្នុងការប្រមូលព័ត៌មានចំណាយ និងការពង្រឹងសមត្ថភាពរបស់មន្ត្រីរាជការក្នុងផ្នែករៀបចំផែនការយុទ្ធសាស្រ្តថវិកា។ នៅក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងចំណូល-ចំណាយក្រៅបរិបទ ក្រសួង-ស្ថាប័ន ក៏បាន និងកំពុងយកចិត្តទុកដាក់ដោយបានធ្វើការណែនាំអង្គភាពក្រោមឱវាទឱ្យរៀបចំថវិកាតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធ្វើសមាហរណកម្មចំណូល-ចំណាយក្រៅបរិបថថវិកាទូទៅក្នុងផែនការថវិកាប្រចាំឆ្នាំ រៀបចំយន្តការផ្ទៃក្នុង និងរៀបចំរបាយការណ៍ចំណូល-ចំណាយប្រចាំខែ ប្រចាំត្រីមាសជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផងដែរ។

នៅក្នុងក្របខ័ណ្ឌការងារសមាហរណកម្មថវិកានេះ រាជរដ្ឋាភិបាលក៏បានបង្កើតក្រុមការងារមួយ (ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងឧត្តមក្រុមប្រឹក្សាសេដ្ឋ

កិច្ចជាតិ) ទទួលបន្ទុកពិនិត្យ និងសម្របសម្រួលដំណើរការសុខដុមនីយកម្មការងារផែនការចំណាយវិនិយោគសាធារណៈរបស់រដ្ឋនិងហិរញ្ញប្បទានសហប្រតិបត្តិការ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏បានសហការជិតស្និទ្ធជាមួយក្រសួងផែនការ និងក្រសួង-ស្ថាប័នដ៏ទៃទៀត រៀបចំផែនការវិនិយោគសាធារណៈ (PIP) ២០១០-២០១២ និងធ្វើការប៉ាន់ប្រមាណចំណាយថវិកាវិនិយោគដោយប្រភពទុនក្នុងស្រុក។

## ៣. បញ្ហាប្រឈម

នៅក្នុងការអនុវត្តផែនការសកម្មភាពកំណែទម្រង់ បញ្ហាប្រឈមមួយចំនួនត្រូវបានលើកឡើងដែលក្នុងនោះរួមមានដូចជា:

- នៅក្នុងវិស័យមួយចំនួន មិនមានមន្ត្រីដែលមានចំណេះដឹង និងជំនាញគ្រប់គ្រាន់ដើម្បីបំពេញការងារ ទន្ទឹមនេះថវិកាគាំទ្រក៏មានកម្រិតដើម្បីធានាការអនុវត្តសកម្មភាពការងារឱ្យមានប្រសិទ្ធភាព។
- កង្វះមធ្យោបាយគាំទ្រ និងឧបករណ៍ប្រើប្រាស់ឆ្លើយតបនឹងតម្រូវការការងារ។
- ការសម្របសម្រួល និងសហការផ្ទៃក្នុង ក្នុងការផ្តល់ ផ្លាស់ប្តូរ និងចែករំលែកទិន្នន័យ និងព័ត៌មាន រវាងអង្គភាព និងអង្គភាព និងឆ្លងក្រសួង-ស្ថាប័ន នៅមិនទាន់មានដំណើរការល្អប្រសើរនៅឡើយ។
- កិច្ចសហការពីក្រសួង-ស្ថាប័នពាក់ព័ន្ធនៅពុំទាន់បានពេញលេញនៅឡើយ ទន្ទឹមនេះការអនុវត្តសកម្មភាពមួយចំនួនរបស់ក្រសួង-ស្ថាប័ន មិនទាន់អាចអនុវត្តបានដោយត្រូវពឹងផ្អែកលើការចាប់ផ្តើមអនុវត្តការងារពីអគ្គនាយកដ្ឋាន នាយកដ្ឋានចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមុនសិន។
- ការជ្រើសរើសទីប្រឹក្សាអន្តរជាតិដើម្បីជួយដល់ផ្នែកលទ្ធកម្មសាធារណៈ និងអគ្គនាយកដ្ឋានរតនាគារជាតិ មិនបានតាមការគ្រោងទុក។
- ការធ្វើរបាយការណ៍តាមដានបំណុលកកស្ទះ និងអាយុកាលបំណុលកកស្ទះ នៅអនុវត្តដោយដៃ។
- ខ្វះខាតជំនាញការផ្នែកច្បាប់ក្នុងផ្នែករៀបចំគោលនយោបាយចំណូលពីប្រេង និងឧស្ម័ន ព្រមជាមួយការខ្វះខាតការគាំទ្រដល់ការស្រាវជ្រាវ ចំណេះដឹងមន្ត្រីមានកម្រិត និងមិនមានព័ត៌មាន និងឯកសារគ្រប់គ្រាន់ពាក់ព័ន្ធនឹងបញ្ហាធ្វើអាជីវកម្មប្រេង និងឧស្ម័ន។
- សារាចររបស់រដ្ឋាភិបាលមិនមានកំលាំងគ្រប់គ្រាន់ក្នុងការដាក់ទណ្ឌកម្មដល់ក្រុមហ៊ុនកាស៊ីណូដែលបង់ពន្ធយឺត និងការពន្យាពេលអនុម័តច្បាប់ស្តីពីការគ្រប់គ្រងកាស៊ីណូ។
- សំណើសុំគោលការណ៍ផ្តល់រង្វាន់លើកទឹកចិត្ត និងនីតិវិធីដកចំណាយសម្រាប់ដំណើរការប្រមូលចំណូល និងអ្នកអនុវត្តប្រមូលចំណូលមិនទាន់មានការសម្រេចជាផ្លូវការ និងការលើកទឹកចិត្តចំពោះមន្ត្រីអនុវត្តការងារកំណែទម្រង់នៅមិនទាន់ឆ្លើយតបតាមតម្រូវការជាក់ស្តែង។
- ការយល់ដឹងអំពីប្រព័ន្ធព័ត៌មានវិទ្យានៅមានកម្រិត និងការជ្រើសរើសមន្ត្រីវិភាគអភិក្រមការងារមិនបានសម្រេចដោយពុំមានបេក្ខជនដែលមានសមត្ថភាពសមស្រប។

- ការបង្កើត និងដំណើរការក្រុមការងារថវិកាក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកានៅតាមក្រសួង-ស្ថាប័ននៅមិនទាន់បានប្រសើរនៅឡើយ។
- ការស្នើសុំឱ្យមានការបង្ហាញពីសមាសភាព និងមូលនិធិដៃគូអភិវឌ្ឍន៍តាមក្រសួង-ស្ថាប័ន មានការលំបាក ដែលជាចំណោទចំពោះការធ្វើសមាហរណកម្មថវិកា។
- ការអនុវត្តកម្មវិធីបណ្តុះបណ្តាលមួយចំនួនមិនអាចដំណើរការបានដោយហេតុមិនអាចប្រើប្រាស់ថវិកាគម្រោងដើម្បីឧបត្ថម្ភដល់គ្រូបង្រៀនជាមន្ត្រីរាជការ។
- ការសម្រេចលើជម្រើសក្នុងការដាក់ឱ្យដំណើរការប្រព័ន្ធស្វ័យប្រវត្តិកម្មនៅអគ្គនាយកដ្ឋានរតនាគារជាតិនៅ មិនទាន់មាននៅឡើយ។

## ៣. សេចក្តីសន្និដ្ឋាន

ជារួម នៅក្នុងឆ្នាំ ២០០៩ កន្លងមក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួនបានចូលរួមអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានទទួលលទ្ធផលគួរជាទីកត់សំគាល់។ ផ្អែកតាមលទ្ធផលដែលសម្រេច និងដោយផ្ទៀងផ្ទាត់ជាមួយសូចនាករដែលបានដាក់ចេញភាពជឿទុកចិត្តបាននៃថវិកានៅតែអាចរក្សាបាន និងមានភាពរឹងមាំដដែល ទោះបីស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុទូទៅមិនមានលក្ខណៈអំណោយផលក៏ដោយ ដែលនេះសបញ្ជាក់អំពីភាពរឹងប៉ឹងនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ដែលជាផ្លែផ្កានៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

សកម្មភាពជំហានទី ១ ដែលត្រូវបន្តពង្រឹងនៅក្នុងដំណាក់កាលទី ២ ត្រូវបានអនុវត្ត និងកំពុងបន្តអនុវត្តដើម្បីសម្រេចគោលបំណងធំៗទាំងបួន ដែលគ្រោងទុក។ ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានគួរជាទីមោទននេះ អង្គភាពពាក់ព័ន្ធគួរមានការយកចិត្តបន្ថែមចំពោះបញ្ហាគន្លឹះមួយចំនួនដូចជា ការរៀបចំនិងដាក់អនុវត្តគោលនយោបាយចំណូលដែលមានប្រសិទ្ធភាព និងឆ្លើយតបនឹងស្ថានភាពកម្ពុជា ការជំរុញរៀបចំក្របខ័ណ្ឌច្បាប់លទ្ធកម្មសាធារណៈ និងការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីក្នុងផ្នែកលទ្ធកម្មសាធារណៈជាដើម។

ចំពោះការអនុវត្តសកម្មភាពជំហានទី ២ ដែលជាសកម្មភាពគោលដើម្បីកែលម្អគណនេយ្យហិរញ្ញវត្ថុ ហើយដែលមានចំនួនសកម្មភាពច្រើន និងស្មុគ្រស្មាញផងនោះ ក៏មានវឌ្ឍនភាពគួរជាទីលើកទឹកចិត្តផងដែរ។ ប៉ុន្តែទោះជាយ៉ាងណា វឌ្ឍនភាពការងារនេះ ក៏មិនទាន់អាចឆ្លើយតបទាំងស្រុងទៅនឹងគោលដៅទាំងអស់ដែលបានកំណត់នៅក្នុងឆ្នាំ ២០០៩ នោះទេ។ នៅក្នុងបញ្ហានេះ យើងអាចកត់សំគាល់ឃើញវឌ្ឍនភាពនៅមានកម្រិតពាក់ព័ន្ធនឹងការកំណត់អង្គភាពថវិកា ការកំណត់បន្ទាត់គណនេយ្យភាពរបស់អ្នក

គ្រប់គ្រងថវិកា និងអង្គភាពថវិកា ការធ្វើវិមជ្ឈការ និងវិសហមជ្ឈការហិរញ្ញវត្ថុ ការវិភាគមុខងារ និងការរៀបចំការបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាពគាំទ្រដល់ការអនុវត្តកម្មវិធីកំណែទម្រង់ជាដើម។ បញ្ហានេះអាចផ្តើមចេញពីការកំណត់គោលដៅមិនមានលក្ខណៈសមស្របតាមតថភាពការងារជាក់ស្តែងនិងការរៀបចំចង្កោមសកម្មភាពមិនទាន់មានលក្ខណៈជាខ្សែសង្វាក់លំដាប់លំដោយល្អប្រសើរ។ មួយវិញទៀត ចង្កោមសកម្មភាពដ៏ច្រើនដែលបានស្នើឡើងអាចហួសពីលទ្ធភាព និងសមត្ថភាពអនុវត្តការងារជាក់ស្តែង។ ទន្ទឹមនេះ យន្តការគាំទ្រផ្នែករដ្ឋបាល ហិរញ្ញវត្ថុ បច្ចេកទេស និងការសម្របសម្រួល គឺជាចំណុចគាំទ្រប្រទាក់ក្រឡាដែលរួមចំណែកដល់ការកំណត់លទ្ធផលនៃការអនុវត្តសកម្មភាពទាំងអស់នេះផងដែរ។

ដោយឡែកសម្រាប់ផែនការសកម្មភាពដែលគាំទ្រដល់គោលបំណងនៃជំហានបន្ទាប់នោះ ត្រូវបានកត់សំគាល់ថាមានវឌ្ឍនភាពគួរជាទីគាប់ប្រសើរ សកម្មភាពជាច្រើនត្រូវបានអនុវត្តឆ្លើយតបនឹងគោលដៅដែលគ្រោងទុក ហើយអាចបង្កើតបានជាមូលដ្ឋានគ្រឹះមួយដ៏ប្រពៃសម្រាប់ការបោះជំហានទៅមុខ។

នៅក្នុងដំណើរការអនុវត្តសកម្មភាពការងារកំណែទម្រង់នេះ បញ្ហាប្រឈមមួយចំនួនត្រូវបានរំលេចឡើងដោយតួអង្គអនុវត្តផ្ទាល់ ដែលការផ្តល់ដំណោះស្រាយ វិធីសាស្ត្រការងារ ក៏ដូចជាការគាំទ្រឆ្លើយតបនឹងតម្រូវការ គឺជាការចាំបាច់ដែលត្រូវមានការយកចិត្តទុកដាក់ដើម្បីធានាឱ្យកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈអាចប្រព្រឹត្តទៅដោយរលូន ប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៅបណ្តាឆ្នាំខាងមុខ។

---------------------